ខែឧសភា ឆ្នាំ២០១២

# បញ្ចប់វដ្តនៃនិទណ្ឌភាពជុំវិញបទល្មើសដោយអាស៊ីដ នៅកម្ពុជា




មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

Cambodian Center for Human Rights

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)

ម.ស.ម.ក គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជា (កម្ពុជា)។ ទស្សនវិស័យរបស់យើង គឺកម្ពុជាគ្មានអំពើហិង្សា ដែលប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសិទ្ធិស្មើគ្នា និងត្រូវបានផ្តល់អំណាច ដើម្បីចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានការចែករំលែកផលប្រយោជន៍ពីការអភិវឌ្ឍន៍ប្រទេសកម្ពុជា។ យើងចង់បាននីតិរដ្ឋជាជាងនិទណ្ឌភាព ស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងសង្គមសេរីពហុបក្សដែលភាពចម្រុះត្រូវបានគេស្វែងរក និងអបអរសាទរជាជាងការមិនអើពើ និងការដាក់ទោស។ ស្លាកសញ្ញារបស់យើង គឺរូបសត្វព្រាបសហើរចេញពីរង្វង់ផ្ទៃមេឃពណ៌ខៀវ ដែលតំណាងឲ្យការទាមទារសេរីភាពនៅកម្ពុជា។

## សេចក្តីថ្លែងអំណរគុណ

របាយការណ៍ "បញ្ចប់វដ្តនៃនិទណ្ឌភាពជុំវិញបទល្មើសដោយអាស៊ីដនៅកម្ពុជា" (របាយការណ៍) ទទួលបានការគាំទ្រផ្នែកមូលនិធិ ពីក្រសួងការបរទេសសហរដ្ឋអាមេរិក។ ម.ស.ម.ក ក៏សូមថ្លែងអំណរគុណចំពោះ អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីដ សម្រាប់ការណែនាំ និងការចូលរួមចំណែកក្នុងការស្រាវជ្រាវសម្រាប់ការសរសេររបាយការណ៍មួយនេះផងដែរ។

រាល់គំនិត របកគំហើញ និងសេចក្តីសន្និដ្ឋាននៅទីនេះ ជាគំនិតរបស់ ម.ស.ម.ក និងមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ឬម្ចាស់ជំនួយដទៃ អ្នកគាំទ្រ និងដៃគូដទៃទៀតនោះទេ។

## សំណួរ ឬការផ្តល់មតិយោបល់កែលម្អ

ប្រសិនបើអ្នកមានសំណួរ ឬចង់បានព័ត៌មានបន្ថែមអំពីរបាយការណ៍នេះ ឬមានបំណងចង់ផ្តល់មតិយោបល់កែលម្អ សូមអ៊ីម៉ែលមកកាន់ info@cchrcambodia.org ។

របាយការណ៍នេះ និងការបោះពុម្ពផ្សាយដទៃទៀតរបស់ ម.ស.ម.ក គឺអាចរកបាននៅលើគេហទំព័ររបស់ ម.ស.ម.ក www.cchrcambodia.org និងគេហទំព័រសិទ្ធិមនុស្ស របស់ ម.ស.ម.ក www.sithi.org ។

(CC) ឆ្នាំ២០១២ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

ផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩ បឹងត្របែក

ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

# មាតិកា


មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ........................................................ i
មាតិកា ........................................................................ ii
និយមន័យ និងអក្សរកាត់................................................................ iii
**១. សេចក្ដីផ្ដើម**.................................................................... 1
វិធីសាស្ត្រស្រាវជ្រាវ ................................................................ 2
**២. ទិដ្ឋភាពទូទៅនៃអំពើហិង្សាដោយអាស៊ីដនៅកម្ពុជា** ......................................... 3
**៣. ទិដ្ឋភាពទូទៅនៃវប្បធម៌និទណ្ឌភាព** ..................................................... 6
និទណ្ឌភាពនៅក្នុងតុលាការកម្ពុជា ..................................................... 7
ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងថ្មី ........................................................ 10
**៤. ការដាក់ពាក្យប្ដឹង** ................................................................ 12
ភាពងាយរងគ្រោះរបស់ជនរងគ្រោះ ..................................................... 12
ការដោះស្រាយក្រៅប្រព័ន្ធតុលាការ ...................................................... 14
ទំនាក់ទំនងរវាងជនរងគ្រោះ និងជនល្មើស ................................................ 15
**៥. ការស៊ើបអង្កេត** ................................................................. 17
ភាពអសកម្មក្នុងការស៊ើបអង្កេត ......................................................... 17
កង្វះខាតការបណ្ដុះបណ្ដាលដ៏សមស្រប ...................................................... 20
កង្វះខាតការសហការពីសាក្សីសំខាន់ ...................................................... 20
អំពើពុករលួយ ...................................................................... 21
**៦. សវនាការ និងសេចក្ដីសម្រេច** ........................................................ 23
ភាពអសកម្មនៃការវិនិច្ឆ័យទោស ......................................................... 23
ការដាក់ទណ្ឌកម្ម និងសំណង ............................................................ 25
ការកាត់ទោស ...................................................................... 25
ការអនុវត្តន៍ទណ្ឌកម្ម ................................................................. 26
**៧. សេចក្ដីសន្និដ្ឋាន និងអនុសាសន៍** ..................................................... 29
**៨. គន្ថនិទ្ទេស** ..................................................................... 32

# និយមន័យ និងអក្សរកាត់

| | |
|---|---|
| ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង | ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង នៅកម្ពុជា |
| អ.ជ.ជ.ក.អ | អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីដ |
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| ក្រមព្រហ្មទណ្ឌ | ក្រមនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា ឆ្នាំ២០០៧ |
| អង្គការ | អង្គការមិនមែនរដ្ឋាភិបាល |
| របាយការណ៍ | បញ្ចប់វដ្តនៃនិទណ្ឌភាពជុំវិញបទល្មើសដោយអាស៊ីដនៅកម្ពុជា |
| រដ្ឋាភិបាល | រាជរដ្ឋាភិបាលកម្ពុជា |

# ១. សេចក្ដីផ្ដើម

នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១២ ស្ត្រីម្នាក់អាយុ ២៣ឆ្នាំ បានរងរបួសរលាកប្រហែលជា៣០ភាគរយ លើរូបរាងកាយរបស់នាង បន្ទាប់ពីរងការវាយប្រហារដោយអាស៊ីដ ខណៈពេលដែលនាងកំពុងតែគេងក្នុងផ្ទះ ក្នុងចម្ការកៅស៊ូ ខេត្តសៀមរាប ហើយដែលការវាយប្រហារនេះត្រូវបានរាយការណ៍ថាប្រហែលជាទាក់ទងនឹងការប្រចណ្ឌ។[1] គិតមកត្រឹមពេលសរសេររបាយការណ៍នេះ ការវាយប្រហារមួយនេះ ជាការវាយប្រហារដោយអាស៊ីដលើកទីបីហើយដែលត្រូវបានរាយការណ៍ បន្ទាប់ពីមានការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំងថ្មីមួយរបស់កម្ពុជា ក្នុងខែធ្នូ ឆ្នាំ២០១១ ដែលមានបំណងគ្រប់គ្រងលទ្ធភាពទទួលបានអាស៊ីដឲ្យបានល្អឡើង (ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង)។[2] ថ្វីបើបទល្មើសនេះមានសភាពធ្ងន់ធ្ងរក៏ដោយ តែនៅមិនទាន់មានការចាប់ខ្លួន និងផ្តន្ទាទោសមកលើជនល្មើសក្នុងករណីវាយប្រហារទាំងបីដែលបានរាយការណ៍នោះទេ។ ក្នុងខែមករា ស្ត្រីម្នាក់ជាកម្មកររោងចក្រត្រូវបានគេស្រោចទឹកអាស៊ីដមកលើខ្លួននាង ខណៈពេលដែលនាងកំពុងតែនៅក្នុងផ្ទះក្នុងខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ[3] និងកាលពីខែមិនា បុរសម្នាក់អាយុ ៤២ឆ្នាំ ត្រូវបាត់បង់ជីវិត និងស្ត្រីម្នាក់អាយុ ១៩ឆ្នាំ បានរងរបួសរលាកធ្ងន់ធ្ងរបន្ទាប់ពីរងការវាយប្រហារដោយអាស៊ីដក្នុងខេត្តកំពង់ចាម ។[4]

នៅកម្ពុជា វប្បធម៌និទណ្ឌភាពស្ថិតនៅជុំវិញអំពើហិង្សាដោយអាស៊ីដ។ ករណីភាគច្រើនជនល្មើសអាចគេចផុតពីការជំនុំជម្រះ និងការផ្តន្ទាទោស បន្ទាប់ពីប្រព្រឹត្តអំពើដ៏ឃោរឃៅនេះរួច។ ការអនុម័តច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងថ្មីមួយនេះ ត្រូវបានមើលឃើញថាជាមធ្យោបាយក្នុងការទប់ស្កាត់អំពើហិង្សាដោយអាស៊ីដ។ ប៉ុន្តែ ការពិតដែលករណីអំពើហិង្សាដោយអាស៊ីដដ៏គួរឲ្យខ្ពើមរអើមទាំងបីកើតមានក្នុងឆ្នាំនេះ ដែលយើងបានដឹង ជនល្មើសនៅមិនទាន់ត្រូវបានចាប់ខ្លួននៅឡើយ បង្ហាញឲ្យឃើញកាន់តែច្បាស់ថា ដើម្បីឲ្យច្បាប់ថ្មីនេះមានប្រសិទ្ធភាព គឺត្រូវតែមានការផ្លាស់ប្តូរដ៏សំខាន់មួយក្នុងបែបបទដែលបទល្មើសនេះត្រូវបានស៊ើបអង្កេត និងវិធីដែលបទល្មើសបែបនេះត្រូវបានជំនុំជម្រះ។ ប្រសិនបើគ្មានការផ្លាស់ប្តូរបែបនេះទេ ច្បាប់ថ្មីនេះនឹងមានប្រសិទ្ធភាពតិចតួច ឯនិទណ្ឌភាពនៅតែបន្ត។ គោលបំណងនៃរបាយការណ៍នេះ គឺដើម្បីជួយដល់រាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល) ក្រសួង

[1] សារព័ត៌មាន ឌឹ ខេមបូឌា ដេលី ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ "ករណីវាយប្រហារដោយអាស៊ីដលើកទីបី ក្នុងឆ្នាំនេះបានទុកឲ្យស្ត្រីម្នាក់រងរបួសធ្ងន់ធ្ងរ", សារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្តិ៍ "ករណីវាយប្រហារលើកទីបី ក្នុងឆ្នាំនេះធ្វើឲ្យជនរងគ្រោះនៅក្នុងមន្ទីរពេទ្យ" ។

[2] ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១២ មានការរាយការណ៍ថា បុរសម្នាក់ អាយុ ២៦ឆ្នាំ បានរងរបួសរលាកដោយអាស៊ីដយ៉ាងធ្ងន់ធ្ងរ ក្នុងខេត្តកំពង់ចាម ក្នុងគ្រោះថ្នាក់ចៃដន្យ ដែលបណ្តាលមកពីការរអិលជាមួយដបប្លាស្ទិកដែលគាត់បានផ្ទុកអាស៊ីដ ធ្វើឲ្យដបនោះបែកហើយស្រោចអាស៊ីដមកលើមុខមាត់ និងដងខ្លួនរបស់គាត់។ សូមអាន សារព័ត៌មាន ឌឹ ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១២ "ច្បាប់អាស៊ីដនៅមិនទាន់ពេញលេញ" ។

[3] សារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្តិ៍ ថ្ងៃទី០២ ខែមិនា ឆ្នាំ២០១២ "ជនល្មើសនៃអំពើហិង្សាដោយអាស៊ីដនៅតែមានសេរីភាព បើយោងតាមមន្ត្រីនគរបាល"

[4] សារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្តិ៍ ថ្ងៃទី១២ ខែមិនា ឆ្នាំ២០១២ "ការវាយប្រហារដោយអាស៊ីដបានផ្តាច់ជីវិតបុរសម្នាក់" ។

មន្ទីរ មន្ត្រីនគរបាល និងចៅក្រម តាមរយៈការពិនិត្យមើលលើការខកខាន និងឧបសគ្គដែលជនរងគ្រោះបានជួបប្រទះក្នុងដំណាក់កាលរាយការណ៍ ស៊ើបអង្កេត និងសវនាការក្នុងដំណើរការយុត្តិធម៌ ដែលជួយជំរុញឲ្យវដ្តនៃនិទណ្ឌភាពកាន់តែរាលដាល ធ្វើឲ្យបញ្ហានៃអំពើហិង្សាដោយអាស៊ីដនៅមានជាបន្ត។

## វិធីសាស្ត្រស្រាវជ្រាវ

របាយការណ៍នេះ វិភាគលើស្ថានភាពនៃអំពើហិង្សាដោយអាស៊ីដនៅកម្ពុជា ជាពិសេស គឺផ្តោតលើដំណើរការយុត្តិធម៌។ ការស្រាវជ្រាវស្តីពីបញ្ហាអំពើហិង្សាដោយអាស៊ីដនៅកម្ពុជា មិនមានច្រើននោះទេ។ ដើម្បីសរសេរនូវរបាយការណ៍នេះ យើងបានប្រើប្រាស់របាយការណ៍ស្តីពីស្ថានភាពអំពើហិង្សាដោយអាស៊ីដមួយចំនួនដែលមានស្រាប់។ មិនតែប៉ុណ្ណោះ យើងក៏បានប្រើប្រាស់ប្រភពសារព័ត៌មានមួយចំនួន រាប់បញ្ចូលទាំង *ឌឹ ភ្នំពេញប៉ុស្តិ៍, ឌឹ ខេមបូឌា ដេលី, វិទ្យុអាស៊ីសេរី និងវិទ្យុសំឡេងសហរដ្ឋអាមេរិក។* ព័ត៌មានជាច្រើននៅក្នុងរបាយការណ៍នេះ ប្រមូលបានតាមរយៈការសម្ភាសន៍ទាំងផ្លូវការ និងមិនផ្លូវការ ដែលធ្វើឡើងរវាងខែតុលា ឆ្នាំ២០១១ ដល់ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២។ ប្រភពទាំងនោះរាប់បញ្ចូលទាំង អ្នកតំណាងមកពីអង្គការមិនមែនរដ្ឋាភិបាល (អង្គការ) ជនរងគ្រោះដោយអាស៊ីដ និងទីប្រឹក្សាផ្នែកច្បាប់។ ករណីសិក្សាដែលមានក្នុងរបាយការណ៍នេះ បានដកស្រង់ចេញតាមរយៈការតាមដានអត្ថបទសារព័ត៌មានរបស់ ម.ស.ម.ក និងតាមរយៈបទសម្ភាសន៍ជាមួយជនរងគ្រោះមកពីអង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីដ (អ.ជ.ជ.ក.អ) ។ ការយោងលើករណីសិក្សាទាំងនេះនឹងធ្វើឡើងក្នុងរបាយការណ៍ទាំងមូល ដើម្បីបង្ហាញនូវបញ្ហាដែលនឹងត្រូវលើកយកមកពិចារណា។ ម.ស.ម.ក សូមរក្សាឈ្មោះជនរងគ្រោះដែលត្រូវបានសម្ភាសទុកជាការសម្ងាត់ ដើម្បីការពារសុវត្ថិភាព ហើយនឹងប្រើឈ្មោះសម្ងាត់ លើកលែងករណីដែល ម.ស.ម.ក បានទទួលការយល់ព្រមពីជនរងគ្រោះឲ្យប្រើឈ្មោះ និងព័ត៌មានលម្អិតរបស់ពួកគេ។ អ្នកដែលត្រូវបានសម្ភាស ត្រូវបានជម្រាបពីគោលបំណងនៃការសម្ភាសន៍ ចរិតលក្ខណៈនៃការស្ម័គ្រចិត្ត និងវិធីដែលព័ត៌មានទាំងនោះនឹងត្រូវយកមកប្រើប្រាស់។ ជនរងគ្រោះដែលត្រូវបានសម្ភាសទាំងនោះ បានបង្ហាញការយល់ព្រមដោយផ្ទាល់មាត់ក្នុងការធ្វើបទសម្ភាសន៍។

# ២. ទិដ្ឋភាពរួមនៃអំពើហិង្សាដោយអាស៊ីដនៅកម្ពុជា

បញ្ហាអំពើហិង្សាដោយអាស៊ីដ បានញាំញីមកលើសង្គមកម្ពុជាអស់រយៈពេលជាយូរណាស់មកហើយ។ យោងតាមទិន្នន័យដែល អ.ជ.ជ.ក.អ ប្រមូលបានតាមរយៈការផ្តល់ការព្យាបាលទៅជនរងគ្រោះ នៅរវាងឆ្នាំ១៩៧៩ និងដើមឆ្នាំ២០១២ មានចំនួនករណីរងគ្រោះដោយសារអាស៊ីដកើតមានចំនួន ២៩៧ករណី ដែលបណ្តាលឲ្យមានជនរងគ្រោះចំនួន ៣៦៤នាក់។[5] រយៈពេលជាច្រើនឆ្នាំកន្លងមក ចំនួនការវាយប្រហារដោយសារអាស៊ីដ មានចំនួនខុសៗគ្នា ពីមួយឆ្នាំទៅមួយឆ្នាំ ដែលមានចំនួនច្រើនបំផុតរហូតដល់ ៤០ករណី ក្នុងឆ្នាំ២០០០[6] ការកើនឡើងនេះ ហាក់ដូចជាកើតមានបន្ទាប់ពីករណីវាយប្រហារមកលើអ្នកសម្តែងចម្រៀងការ៉ាអូខេ តាត ម៉ារីណា ដែលមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយ កាលពីខែធ្នូ ឆ្នាំ១៩៩៩។[7] ចំនួនករណីវាយប្រហារដោយសារអាស៊ីដដែលបានរាយការណ៍ មានការធ្លាក់ចុះប្រហែលពាក់កណ្តាលក្នុងឆ្នាំ២០១១ យោងតាមទិន្នន័យរបស់ អ.ជ.ជ.ក.អ គឺធ្លាក់ចុះពី ១៩ករណី ដែលមានជនរងគ្រោះ ៣៦នាក់កាលពីឆ្នាំមុន មកត្រឹមចំនួន១០ករណី ដែលមានជនរងគ្រោះ ១៦នាក់ ក្នុងឆ្នាំ២០១១។[8] មានបុគ្គលមួយចំនួនបានលើកឡើងថា ការចាប់អារម្មណ៍មកលើច្បាប់អាស៊ីដថ្មី ដើម្បីគ្រប់គ្រងលើលទ្ធភាពទទួលបានអាស៊ីដ និងដើម្បីដាក់ទោសមកលើជនល្មើសដែលទើបនឹងអនុម័តដោយព្រឹទ្ធសភា កាលពីខែវិច្ឆិកា ឆ្នាំ២០១១នេះ អាចបណ្តាលឲ្យករណីវាយប្រហារដោយអាស៊ីដធ្លាក់ចុះ ទោះបីជាការធ្លាក់ចុះនេះប្រហែលអាចមកពីករណីវាយប្រហារមួយចំនួនមិនត្រូវបានរាយការណ៍។[9] ខណៈពេលដែលករណីវាយប្រហារដោយអាស៊ីដមានការធ្លាក់ចុះក្នុងពេលថ្មីៗនេះ តែមនុស្សជាច្រើនគិតថា "ចំនួនងងឹត" ដែលជាចំនួនការវាយប្រហារមិនបានរាយការណ៍ អាចមានចំនួនខ្ពស់ប្រហាក់ប្រហែលនឹង ចំនួនដែលត្រូវបានរាយការណ៍ដែរ ។[10]

> នាង នេត្រា និយាយថាលោកមិនបានដឹងថាហេតុអ្វីបានជាគេជះទឹកអាស៊ីដមកលើរូបលោកក្នុងពេលយប់អាធ្រាតខណៈពេលដែលលោកកំពុងតែដេកក្នុងផ្ទះ។ លោកមិនធ្លាប់ឈ្លោះប្រកែកជាមួយអ្នកណានោះទេ។ លោកគិតថាលោកត្រូវគេវាយប្រហារ ដោយសារតែលោកមានមិត្តស្រី។ លោកសង្ស័យថា ជនល្មើសជាអ្នករស់នៅក្នុងភូមិជាមួយលោកដែរ ។

[5] ព័ត៌មានទទួលបានពី អ.ជ.ជ.ក.អ ។

[6] អ.ជ.ជ.ក.អ និង ម.ស.ម.ក ខែឧសភា ឆ្នាំ២០១០ "យើងនាំគ្នាបញ្ឈប់អំពើហិង្សាដោយអាស៊ីដ នៅកម្ពុជា" ទំព័រទី៤២ ។

[7] មជ្ឈមណ្ឌល អាវ៉ែន ពិភពលោកសម្រាប់ស្ត្រី និងយុត្តិធម៌ គណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្សអន្តរជាតិនៃគណៈមេធាវីរដ្ឋញូវយ៉ក គ្រឹះស្ថានសិទ្ធិមនុស្សនៃសាលាច្បាប់អន្តរជាតិខរណែល និងមូលនិធិគុណធម៌ ឆ្នាំ២០១១ របាយការណ៍ "លុបបំបាត់អំពើហិង្សាដោយអាស៊ីដនៅប្រទេស បង់ក្លាដែស ឥណ្ឌា និងកម្ពុជា" ទំព័រទី១០ ។

[8] សារព័ត៌មាន ឌឹ ខែមបូឌា ដេលី ថ្ងៃទី០៤ ខែមករា ឆ្នាំ២០១២ "ចំនួនករណីវាយប្រហារដោយអាស៊ីដ ធ្លាក់ចុះជិតពាក់កណ្តាលក្នុងអំឡុងឆ្នាំ២០១១" ។

[9] ដូចខាងលើ។

[10] សូមអាន របាយការណ៍ប្រចាំឆ្នាំ ២០០៩ របស់ អ.ជ.ជ.ក.អ អាចអានបាន ៖ www.cambodianacidsurvivorscharity.org/annual%20report2009.pdf ។

នៅកម្ពុជា ការវាយប្រហារដោយអាស៊ីដ ជាទូទៅគឺជាលទ្ធផលនៃ ឬក៏ត្រូវបានគិតថាជាមធ្យោបាយ ដោះស្រាយបញ្ហា ដែលភាគច្រើន អាចបណ្តាលមកពីបញ្ហាគ្រួសារ ឬទំនាក់ទំនងផ្ទាល់ខ្លួន។[11] អារម្មណ៍ប្រចណ្ឌ ខឹងសម្បារ និងការសងសឹក ក៏ហាក់ដូចជាកត្តាជំរុញដ៏ខ្លាំងក្លាមួយ ហើយដែល អ.ជ.ជ.ក.អ បានកត់សម្គាល់ថាចំនួនភាគច្រើននៃករណីវាយប្រហារកើតឡើងមកពីភាពស្អប់-ខ្ពើម និងការប្រចណ្ឌ/ប្រចណ្ឌ ។ ឧទាហរណ៍ "*មូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើន ដែលបណ្តាលឲ្យមានការវាយប្រហារ គឺការសងសឹកព្រោះតែការក្បត់ចិត្ត។ ភរិយានៃស្វាមីដែលក្បត់ចិត្តវាយប្រហារមកលើស្រីកំណាន់របស់ស្វាមីខ្លួន ឬក្នុងករណីមួយវិញទៀត ស្រីកំណាន់បានវាយប្រហារមកលើភរិយារបស់គូស្នេហ៍នាងវិញ*"។[12] ជម្លោះអាជីវកម្ម និងជម្លោះដីធ្លី ក៏ជាកត្តាជំរុញឈានមុខមួយដែរ ទោះបីជាក្នុងករណីជាច្រើន មិនអាចសន្និដ្ឋានដឹងពីមូលហេតុនៃការវាយប្រហារ និងរកជនល្មើសមិនឃើញក៏ដោយ។

នៅកម្ពុជា អ្នកប្រព្រឹត្តបទល្មើសមានទាំងបុរស និងស្ត្រី ទោះបីជា "*របាយការណ៍បង្ហាញថាជនល្មើសភាគច្រើនជាស្ត្រី*"[13] ស្ត្រីជាភរិយាវាយប្រហារមកលើស្រីកំណាន់របស់ស្វាមី ឬស្រីកំណាន់វាយប្រហារមកលើភរិយាដើមវិញ។ មានហេតុផលជាច្រើន ដែលអាស៊ីដត្រូវបានជ្រើសយកមកធ្វើជាអាវុធដើម្បីវាយប្រហារនៅកម្ពុជា។ តាមការកត់សម្គាល់ ភាពងាយស្រួលក្នុងការរកទិញអាស៊ីដ តម្លៃថោក ភាពងាយស្រួលក្នុងការយកតាមខ្លួន និងប្រើប្រាស់ដោយគ្មានការទាក់ទាញចំណាប់អារម្មណ៍ ជាពិសេសការកាន់កាប់អាស៊ីដ គឺស្របច្បាប់ទាំងស្រុង ចំណុចទាំងនេះជាកត្តាសំខាន់ដែលអាស៊ីដត្រូវបានយកមកប្រើក្នុងការវាយប្រហារ។ សម្រាប់ប្រជាពលរដ្ឋកម្ពុជាភាគច្រើន អាស៊ីដជាវត្ថុសំខាន់ក្នុងជីវភាពប្រចាំថ្ងៃ ព្រោះមានការប្រើប្រាស់អាស៊ីដ ក្នុងវិស័យជាច្រើន ដូចជា ចម្ការកៅស៊ូជាដើម។ ការទិញអាស៊ីដ ងាយស្រួលជាងការទិញអាវុធដែលបណ្តាលឲ្យមានគ្រោះថ្នាក់ដទៃទៀត ដូច កាំភ្លើង ប៉ុន្តែធ្វើឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាដែរ។[14]

---

កែវ មេត្តា ត្រូវភរិយារបស់លោកវាយប្រហារក្នុងឆ្នាំ២០០៩ បន្ទាប់ពីនាងបានដឹងថាលោកមិនបានទៅធ្វើការដែលលោកជានគរបាល ប៉ុន្តែ បែរជាទៅរកមិត្តស្រីរបស់លោកវិញ។ ភរិយារបស់លោកបានទិញអាស៊ីដពីអ្នកលក់អាគុយនៅផ្សារ ។ លោកត្រូវពិការភ្នែកទាំងសងខាង។ លោកសំណូមពរឲ្យអ្នកលក់អាស៊ីដទាំងអស់ ត្រូវតែសុំច្បាប់អនុញ្ញាត្តពីអាជ្ញាធរមុននឹងលក់អាស៊ីដ ព្រមទាំងមានលក្ខខណ្ឌដ៏តឹងរឹងសម្រាប់គ្រប់គ្រងអ្នកដែលមានបំណងទិញអាស៊ីដ ។

---

[11] អ.ជ.ជ.ក.អ និង ម.ស.ម.ក កំណត់សម្គាល់បន្ថែម ទំព័រទី៤។

[12] ដូចខាងលើ ទំព័រទី៤។

[13] ដូចខាងលើ ទំព័រទី៣។

[14] ដូចខាងលើ ទំព័រទី៨។

នៅកម្ពុជា ទស្សនៈសាធារណជនចំពោះជនរងគ្រោះដោយអាស៊ីដ និងការរើសអើងដែលពាក់ព័ន្ធនឹងអំពើហិង្សាដោយអាស៊ីដ ជះឥទ្ធិពលយ៉ាងខ្លាំងលើអំពើហិង្សាដោយអាស៊ីដ។[15] ពេលខ្លះទំនោរនៃទស្សនៈសាធារណជនចំពោះជនរងគ្រោះគឺ ពួកគេស័ក្តិសមនឹងទទួលការវាយប្រហារបែបនេះជាលទ្ធផល ដោយសារតែអ្នកទាំងនោះបានធ្វើខុស។ អាកប្បកិរិយាបែបនេះ អាចផ្តល់ភាពស្រប-ច្បាប់ចំពោះការវាយប្រហារ និងរួមចំណែកឲ្យព្រឹត្តិការណ៍បែបនេះកើតឡើង ដូចក្នុងករណីភាពអសកម្មក្នុងដំណើរការយុត្តិធម៌ជុំវិញអំពើហិង្សាដោយអាស៊ីដ ដែលនឹងត្រូវយកមកពិភាក្សាក្នុងជំពូកទី៤ ក្នុងរបាយការណ៍នេះ។

[15] ដូចខាងលើ ទំព័រទី២៧។

# ៣. និដ្ឋភាពទូទៅនៃវប្បធម៌និទណ្ឌភាព

> *"និទណ្ឌភាពមានន័យថា តាមការអនុវត្តជាក់ស្តែង គឺភាពមិនអាចនាំយកជនល្មើស នៃទង្វើរំលោភបំពានមកទទួលខុសត្រូវ ទាំងក្នុងករណីព្រហ្មទណ្ឌ រដ្ឋប្បវេណី រដ្ឋបាល ឬក៏វិធានការវិន័យព្រោះគ្មានការស៊ើបអង្កេតណាមួយមកលើជនល្មើស ដែលអាចនាំទៅរកការចាប់ខ្លួន ជំនុំជម្រះ និងផ្តន្ទាទោសឲ្យត្រឹមត្រូវ ប្រសិនបើរកឃើញថាមានកំហុស និងដើម្បីផ្តល់សំណងដល់ជនរងគ្រោះ" ។*
>
> *(បណ្តុំគោលការណ៍ដើម្បីការការពារ និងលើកដម្កើងសិទ្ធិមនុស្សតាមរយៈសកម្មភាពបំបាត់និទណ្ឌភាព របស់អង្គការសហប្រជាជាតិ ខែកុម្ភៈ ឆ្នាំ២០០៥ ។)*

បញ្ហានិទណ្ឌភាព បានរីករាលដាលយ៉ាងខ្លាំងក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជាទាំងមូល មិនត្រឹមតែពាក់ព័ន្ធនឹងបទល្មើសដោយអាស៊ីដនោះទេ។ ពេលពិភាក្សារឿងនិទណ្ឌភាព យើងមានន័យថាជាការខកខានមិនបាននាំជនល្មើសមកផ្តន្ទាទោស។ បណ្តុំគោលការណ៍ដើម្បីការការពារ និងលើកដម្កើងសិទ្ធិមនុស្ស តាមរយៈសកម្មភាពបំបាត់និទណ្ឌភាព របស់អង្គការសហប្រជាជាតិ ចែងថា *"និទណ្ឌភាពបណ្តាលពីការខកខានរបស់រដ្ឋ ដើម្បីបំពេញកាតព្វកិច្ច ស៊ើបអង្កេតលើការរំលោភបំពាន ចាត់វិធានការឲ្យបានសមស្របចំពោះជនល្មើស ជាពិសេសក្នុងរឿងយុត្តិធម៌ ដោយធានាថាជនសង្ស័យដែលអាចមានទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌ នឹងត្រូវបានយកមកចោទប្រកាន់ ជំនុំជម្រះ និងផ្តន្ទាទោសឲ្យបានស័ក្តិសម ដើម្បីឲ្យជនរងគ្រោះទទួលបានការដោះស្រាយយ៉ាងសមស្រប និងធានាថាពួកគេបានទទួលនូវសំណងសម្រាប់ព្យសនកម្មដែលពួកគេបានទទួល" ។*[16]

និទណ្ឌភាព គឺជាបដិសំយោគ នៃដំណើរការដ៏សមស្រប និងយុត្តិធម៌។ សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ស្តីពី គោលការណ៍មូលដ្ឋាន របស់អង្គការសហប្រជាជាតិ ស្តីពីយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារបទល្មើស និងការប្រើអំណាចខុសច្បាប់ ដែលចែងថា *"ជនរងគ្រោះគួរតែត្រូវបានប្រណិបត្តិដោយសេចក្តីមេត្តា និងការគោរពលើកិត្តិយសរបស់ពួកគេ។ ពួកគេត្រូវមានលទ្ធភាពទទួលបានយន្តការដើម្បីភាពយុត្តិធម៌ និងដើម្បីឲ្យមានការដោះស្រាយឲ្យឆាប់រហ័ស ពីសំណាក់ប្រព័ន្ធយុត្តិធម៌ជាតិ"*។[17] បន្ថែមពីលើនោះគោលការណ៍នេះបានចែងថា *"យន្តការយុត្តិធម៌ និងរដ្ឋបាលត្រូវតែបង្កើតឡើង និងពង្រឹងនៅពេលណាចាំបាច់ ដើម្បីអាចធ្វើឲ្យជនរងគ្រោះទទួលបានការដោះស្រាយ*

---

[16] ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម របស់អង្គការសហប្រជាជាតិ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៥ "បណ្តុំគោលការណ៍ ដើម្បីការការពារ និងលើកដម្កើងសិទ្ធិមនុស្ស តាមរយៈសកម្មភាពបំបាត់និទណ្ឌភាព របស់អង្គការសហប្រជាជាតិ " E/CN.4/2005/102/Add 1 ទំព័រទី៧។

[17] គោលការណ៍មូលដ្ឋាន របស់ អង្គការសហប្រជាជាតិ ស្តីពីយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារបទល្មើស និងការរំលោភបំពានអំណាច ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ សេចក្តីប្រកាសរបស់មហាសន្និបាត លេខ៤០/៣៤ គោលការណ៍លេខ៤។

*ទាំងតាមរយៈដំណើរការផ្លូវការ និងមិនផ្លូវការ ដែលមានលក្ខណៈឆាប់រហ័ស មានយុត្តិធម៌ មានតម្លៃសមរម្យ និងមានលទ្ធភាពទទួលយកបាន" ។*[18]

មុននឹងយើងពិនិត្យមើលលើបញ្ហាជាក់ស្តែង ដែលប៉ះពាល់ដល់លទ្ធភាពទទួលបានយុត្តិធម៌ ក្នុងករណីអំពើហិង្សាដោយអាស៊ីដក្នុងដំណាក់កាលនីមួយៗនៃដំណើរការយុត្តិធម៌ ជំពូកនេះនឹងពិនិត្យមើលបញ្ហាសំខាន់បំផុត ពាក់ព័ន្ធនឹងនិទណ្ឌភាព និងអំពើហិង្សាដោយអាស៊ីដនៅកម្ពុជា ។

## និទណ្ឌភាពក្នុងតុលាការកម្ពុជា

កង្វះឯករាជ្យភាពក្នុងប្រព័ន្ធតុលាការកម្ពុជា នៅបន្តជាកត្តាដ៏សំខាន់បំផុតមួយដែលរារាំងកម្ពុជាមិនឲ្យអភិវឌ្ឍន៍នូវសង្គមមួយដែលមានយុត្តិធម៌ ភាពត្រឹមត្រូវ និងចុះសម្រុង អាស្រ័យលើនីតិរដ្ឋ។ ក្នុងខែតុលា ឆ្នាំ២០១០ របាយការណ៍របស់អ្នកតំណាងពិសេសស្តីពីបញ្ហាសិទ្ធិមនុស្សនៅកម្ពុជា លោក សូរិយា ស៊ូប៊េឌី បានរកឃើញថា *"អំពើពុករលួយហាក់ដូចជារីករាលដាលក្នុងកម្រិតទាំងអស់នៃប្រព័ន្ធយុត្តិធម៌"* [19] ខណៈពេលដែលមានសេចក្តីប្រកាស ខែតុលា ឆ្នាំ២០១០ របស់សភាអឺរ៉ុប បានពិពណ៌នាថាប្រព័ន្ធយុត្តិធម៌គឺ *"នៅបន្ទាប់ពីបញ្ហានយោបាយ"*។ [20] កាលពីឆ្នាំមុន បងប្អូនជីដូនមួយរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានរកឃើញថាមានទោស ដោយសារអំពើពុករលួយ និងត្រូវផ្តន្ទាទោសកំបាំងមុខឲ្យជាប់ពន្ធនាគារចំនួន២ឆ្នាំ កន្លះ នៅតែអាចដើរហើរដោយសេរីនៅក្នុងទីក្រុងភ្នំពេញ ហើយដែលចៅក្រមទទួលបន្ទុករឿងក្តីនេះគេចមិនព្រមចេញដីកាចាប់ខ្លួន។[21] សេចក្តីសម្រេចនេះ ជាឧទាហរណ៍យ៉ាងច្បាស់ពីការបែកដាច់រវាងអ្នកមាន និងអ្នកមានទំនាក់ទំនងល្អចេញពីជនក្រីក្រ និងដាច់ស្រយាលនៅកម្ពុជា និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។[22]

ករណីវាយប្រហារដែលគេបានដឹងឮជាច្រើននៅកម្ពុជា ជួយជំរុញបន្ថែមដល់ទស្សនៈរបស់ប្រជាពលរដ្ឋសាមញ្ញ ថាប្រព័ន្ធយុត្តិធម៌គឺសម្រាប់តែបម្រើអ្នកមាន និងអ្នកមានអំណាចតែប៉ុណ្ណោះ។ មេធាវីរបស់ ឧត្តមសេនីយ៍ត្រី លោកស្រី ជា រដ្ឋា មេបញ្ជាការនគរបាលជាតិ ក្នុងខែសីហា ឆ្នាំ២០០៩ បានដោគជ័យក្នុងការការពារក្តីឲ្យលោកស្រីនៅសាលាដំបូង ពីបទចោទប្រកាន់ថាបានបញ្ជាឲ្យមានការ

---

[18] ដូចខាងលើ គោលការណ៍លេខ៥។

[19] អ្នកតំណាងពិសេសទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ខែកញ្ញា ឆ្នាំ២០១០ "របាយការណ៍របស់អ្នកតំណាងពិសេសទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា A/HRC/15/46 ទំព័រទី១៣។

[20] សភាអឺរ៉ុប ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០ "សេចក្តីប្រកាសរបស់សភាអឺរ៉ុប នៅថ្ងៃទី២១ ខែតុលា ឆ្នាំ ២០១០ នៅកម្ពុជា ជាពិសេសក្នុងករណី លោក សម រង្ស៊ី" កំណត់ហេតុផ្លូវការរបស់សហភាពអឺរ៉ុប C/70 E/10 ។

[21] សារព័ត៌មាន ឌឹ ខែមបូឌា ដេលី ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ "ដីកាចាប់ខ្លួនបងប្អូនជីដូនមួយលោកហ៊ុន សែន ហាក់ដូចជាមិនត្រូវបានចេញដោយឆាប់រហ័សនោះទេ" ។

[22] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១១ "វិចារណកថាព័ត៌មាន ៖ ការខកខានមិនព្រមចេញដីកាចាប់ខ្លួន បងប្អូនជីដូនមួយរបស់លោកនាយករដ្ឋមន្ត្រី បង្ហាញពីវប្បធម៌និទណ្ឌភាពនៅកម្ពុជា" អាចអានបាន ៖ http://www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=202&id=5 ( ចូលអានលើកចុងក្រោយ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២ )។

វាយប្រហារដ៏ឃោរឃៅ មកលើសាច់ញាតិគូស្នេហ៍របស់លោកស្រី។ មេធាវីរបស់លោកស្រីបានធ្វើការស្នើសុំទៅ លោក សុខ អាន រដ្ឋមន្រ្តីទទួលបន្ទុកគណៈរដ្ឋមន្រ្តី មុនពេលការជំនុំជម្រះរបស់សាលាឧទ្ធរណ៍ ដើម្បីឲ្យលទ្ធផលនៃសវនាការមានប្រៀបមកលើខ្លួន បើយោងតាមលិខិតដែល សារព័ត៌មាន ឌឹ ខែមបូឌា ដេលី ទទួលបាន។[23] មេធាវីការពារក្តីរបស់លោកស្រី ជា រដ្ឋា សរសេរថា *"ខ្ញុំសូមសំណូមពរ ឯកឧត្តម ឧបនាយករដ្ឋមន្រ្តី មេត្តាធ្វើអន្តរាគមន៍ក្នុងតុលាការចំពោះករណីនេះ ដើម្បីឲ្យមានការដកពាក្យបណ្តឹង ប្រឆាំងនឹងអតិថិជនរបស់ខ្ញុំ"* ។[24] សកម្មភាពទាំងនេះហើយ ដែលធ្វើឲ្យប្រជាពលរដ្ឋសាមញ្ញគិតថា ប្រព័ន្ធយុត្តិធម៌គឺមិនមែនដើម្បីជួយដល់ជនងាយរងគ្រោះ និងជនដាច់ស្រយាលនោះទេ ប៉ុន្តែជាឧបករណ៍សម្រាប់អ្នកមាន អ្នកមានអំណាច និងអ្នកមានទំនាក់ទំនងល្អដើម្បីគេចវេះពីប្រព័ន្ធយុត្តិធម៌ ។

---

*"ពួកគេមិនបានផ្តល់យុត្តិធម៌ឲ្យខ្ញុំសោះ ប៉ុន្តែជាបែរផ្តល់ការការពារយ៉ាងពេញទំហឹងសម្រាប់ជនល្មើស"*

\- តាត ម៉ារីណា[25]

---

ពាក់ព័ន្ធនឹងករណីអំពើហិង្សាដោយអាស៊ីដ និទណ្ឌភាពនៅក្នុងតុលាការកម្ពុជា ប្រហែលជាអាចបង្ហាញកាន់តែច្បាស់តាមរយៈករណីវាយប្រហារដ៏ល្បីល្បាញមួយនៅកម្ពុជា។ ក្នុងឆ្នាំ ១៩៩៩ តាត ម៉ារីណា ដែលមានអាយុត្រឹមតែ១៥ឆ្នាំ កំពុងទទួលទានបបរជាមួយក្មួយស្រីរបស់នាង ក្នុងផ្សារមួយនៅទីក្រុងភ្នំពេញ រងការវាយប្រហារយ៉ាងឃោរឃៅទាំងកណ្តាលថ្ងៃ និងត្រូវបានស្រោចដោយទឹកអាស៊ីដជាច្រើនលីត្រ។ ទោះបីជាមានសាក្សីប្រហែលជា ២០នាក់នៅកន្លែងកើតហេតុ ប៉ុន្តែជនល្មើសមិនត្រូវបានចាប់ខ្លួននោះទេ។ នេះត្រូវបានគេយល់ឃើញថា ព្រោះតែជនល្មើសមេខ្លោង គឺលោកស្រី ឃួន សុផល ជាភរិយារបស់ លោក ស្វាយ ស៊ីថា បច្ចុប្បន្នជារដ្ឋលេខាធិការនៅ គណៈរដ្ឋមន្រ្តី ដែលជាអតីតគូស្នេហ៍របស់ តាត ម៉ារីណា។ ប៉ុន្តែ នៅឆ្នាំ២០១១ បន្ទាប់ពីការនៅស្ងៀមស្ងាត់អស់ជាងមួយទសវត្សរ៍មក មុនពេលដែលសេចក្តីព្រាងច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងត្រូវបានលើកយកមកពិភាក្សាក្នុងរដ្ឋសភា រដ្ឋាភិបាលបើកកកាយថា តាមការពិត ករណីនេះត្រូវបានបញ្ជូនទៅតុលាការដោយស្ងាត់ៗក្នុងឆ្នាំ២០០១ ដែល តាត ម៉ារីណា មិនបានដឹងពីរឿងនេះទេ ហើយជនល្មើសត្រូវបានកាត់ទោសដោយកំបាំងមុខ ហើយទណ្ឌកម្មនេះមិនស័ក្តិសមនឹងបទល្មើស ដោយឲ្យជាប់ពន្ធនាគារចំនួន ១ឆ្នាំ

---

[23] សារព័ត៌មាន ឌឹ ខែមបូឌា ដេលី ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ "មេធាវីស្វែងរកជំនួយពីលោក សុខ អាន ក្នុងករណីការវាយប្រហារដោយអាស៊ីដ" ។

[24] ដូចដែលបានដកស្រង់ក្នុងកំណត់សម្គាល់លេខ ២៣, សារព័ត៌មាន ឌឹ ខែមបូឌា ដេលី ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩។

[25] សារព័ត៌មាន ឌឹ ខែមបូឌា ដេលី ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១១ "ការទើបតែបង្ហាញពីសាលក្រមនៃអំពើហិង្សាដោយអាស៊ីដគឺជាព័ត៌មានថ្មីសម្រាប់ តាត ម៉ារីណា" ។

ដោយព្យួរទោស។[26] យោងទៅតាមសេចក្តីសម្រេចកាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ តុលាការសម្រេចផ្តន្ទាទោស "*យួន សុផល អាយុ ៤១ឆ្នាំ ឲ្យជាប់ពន្ធនាគារ ១ឆ្នាំ តែទោសនេះត្រូវព្យួរដោយមានរយៈពេលសាកល្បង ៥ឆ្នាំ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះ ចំពោះករណីវាយប្រហារកាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ១៩៩៩" ។*[27] លោកស្រី យួន សុផល មិនដែលឃើញជាប់ក្នុងពន្ធនាគារឡើយ។

---

សោម រស្មី ជាស្រីកំណាន់របស់ លឹម សុខហេង ដែលជាវរសេនីយ៍ឯកយោធា។ ភរិយារបស់ លឹម សុខហេង បានវាយប្រហារ និងជះទឹកអាស៊ីដចំនួនកន្លះដបមកលើនាងនៅមុខសាក្សីជាច្រើនក្នុងឆ្នាំ២០០១។ លឹម សុខហេង និង សោម រស្មី មានកូនម្នាក់ ហើយខណៈពេលដែល សោម រស្មី កំពុងតែព្យាបាលក្នុងមន្ទីរពេទ្យ លឹម សុខហេង និងភរិយា បានយកកូនដែលមានអាយុ៧ខែ ទៅបាត់។ ពេលដែល សោម រស្មី ដាក់ពាក្យប្តឹងចំពោះស្វាមីភរិយាទាំងពីរ តុលាការបានធ្វើការសម្រេចថា លឹម សុខហេង ធ្វើនេះព្រោះតែការប្រចណ្ឌដែលអាចទទួលយកបាន ដូច្នេះបដិសេធការស្នើសុំយកកូននាងមកវិញ។ ភរិយារបស់លោក ត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចំនួន២ឆ្នាំ។ ឆ្លុះបញ្ចាំងលើករណីរបស់នាង សោម រស្មី បាននិយាយថា "*អ្នកមាន និងអ្នកក្រគឺខុសគ្នាទាំងស្រុង។ ពន្ធនាគារគឺសម្រាប់តែអ្នកក្រប៉ុណ្ណោះ។ ប៉ុន្តែមនុស្សដូចជា លឹម សុខហេង និងភរិយា អាចធ្វើអ្វីក៏បាន និងមិនចាំបាច់ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់នោះទេ" ។*[28]

---

ករណីខាងលើ ជាពិសេសពាក់ព័ន្ធនឹងការផ្តន្ទាទោសដ៏ស្រាល ជាឧទាហរណ៍ដោយចំៗ មួយចំពោះវប្បធម៌និទណ្ឌភាព ដែលកំពុងតែរីករាលដាលនៅក្នុងប្រព័ន្ធយុត្តិធម៌នៃប្រទេសកម្ពុជា ជាពិសេស នៅពេលដែលជនល្មើសជាអ្នកមានអំណាច មានទំនាក់ទំនងល្អ និងមានទ្រព្យ។ ករណីទាំងនេះ បង្ហាញពីការខកខានរបស់អាជ្ញាធរ មិនត្រឹមតែក្នុងការបង្ការសាធារណជនពីការប្រព្រឹត្តបទល្មើសដែលក្នុងលក្ខខណ្ឌជាក់លាក់មួយចំនួន គឺស្មើនឹងការបំពានលើការហាមឃាត់ការប្រព្រឹត្តអំពើទារុណកម្ម និងការប្រណិបត្តិមកលើអ្នកដទៃដោយអំពើឃោរឃៅឯទៀត ដោយអំពើអមនុស្សធម៌ ឬបន្ថោកបន្ទាប និងការរំលោភលើសិទ្ធិរស់រានមានជីវិត ក៏ប៉ុន្តែថែមទាំងខកខានក្នុងការចាត់វិធានការសមស្របដើម្បីធានានូវយុត្តិធម៌ផងដែរ។ ឧទាហរណ៍ លោកស្រី ជា រដ្ឋា នៅមិនត្រូវបានចាប់ខ្លួន ទោះបីជាសាលាឧទ្ធរណ៍បានផ្តន្ទាទោសលោកស្រីជាប់ពន្ធនាគារចំនួន ១៨ឆ្នាំក៏ដោយ។ [29] ទស្សនៈទូទៅគឺប្រសិនបើនគរបាល និងអាជ្ញាធរពិតជាមានបំណងចង់ចាប់ខ្លួននរណាម្នាក់ ពួកគេពិតជាមានធនធាន និងអាចប្រើធនធានទាំងនោះដើម្បីចាប់ខ្លួនជនល្មើសនោះ មិនថាពួកគេនៅទីណាទេ។ ដូចករណី

---

[26] ដូចខាងលើ។

[27] ដូចការដកស្រង់ក្នុង សារព័ត៌មាន ឌឹ ខែមបូឌា ដេលី ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១១ "របាយការណ៍បានបង្ហាញពីការវិនិច្ឆ័យទោស នៃករណីវាយប្រហារដោយអាស៊ីដក្នុងឆ្នាំ១៩៩៩" ។

[28] សារព័ត៌មាន ឌឹ ញូវ យ៉ក ថាមស៍ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០១ "ការសងសឹកបានបំផ្លាញមុខមាត់ និងព្រលឹងនៅកម្ពុជា" ។

[29] ក្នុងឆ្នាំ២០០៩ មន្ត្រីរដ្ឋាភិបាលបាននិយាយថា លោកស្រី ជា រដ្ឋា កំពុងគេចខ្លួនក្នុងប្រទេសថៃ ដែលជាប្រទេសជិតខាង។ សូមអាន សារព័ត៌មាន ឌឹ ខែមបូឌា ដេលី ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ "ជនល្មើសក្នុងអំពើហិង្សាដោយអាស៊ីដ រត់គេចខ្លួនទៅប្រទេសថៃ តាមសម្តីរបស់មន្ត្រី" ។

លោក ហេង ពៅ មេបញ្ជាការនគរបាលនៅទីក្រុងភ្នំពេញ និងជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដែលត្រូវបានចាប់ខ្លួនក្នុងទីក្រុងកូឡាឡាំពួរ និងបានធ្វើបត្យាប័នមកកម្ពុជា ដែលឥឡូវនេះកំពុងជាប់ពន្ធនាគារ ដោយការផ្តន្ទាទោសពីបទចោទប្រកាន់ជាច្រើន រួមមាន អំពើមនុស្សឃាត និងការប៉ុនប៉ងធ្វើមនុស្សឃាត ដែលជាឧទាហរណ៍មួយចំនួន។

## ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងថ្មី

មកទល់ពេលថ្មីៗនេះ បញ្ហានិទណ្ឌភាពជុំវិញអំពើហិង្សាដោយអាស៊ីដ ត្រូវបានជំរុញបន្ថែមដោយភាពខ្វះខាតក្នុងនីតិកម្មព្រហ្មទណ្ឌ ក្នុងការដោះស្រាយបញ្ហាអំពើហិង្សាដោយអាស៊ីដ។ ច្បាប់នេះ មិនបានចែងពីបញ្ញត្តិជាក់លាក់ដើម្បីចាត់ទុកអំពើហិង្សាដោយអាស៊ីដជាបទល្មើសដោយផ្ទាល់នោះទេ ជាលទ្ធផល បញ្ញត្តិដទៃទៀតត្រូវបានប្រើដើម្បីផ្តន្ទាទោសចំពោះអំពើហិង្សាដោយអាស៊ីដ ក្នុងលក្ខណៈមិនជាក់លាក់។ ឧទាហរណ៍ អំពើហិង្សាដោយអាស៊ីដ តែងតែត្រូវបានផ្តន្ទាទោសក្នុងទម្រង់ជាការប្រទូសរ៉ាយ ឬជាអំពើហិង្សាដោយចេតនា ដោយមិនបានរាប់បញ្ចូលនូវចរិតលក្ខណៈដ៏ឃោរឃៅនៃអំពើហិង្សាដោយអាស៊ីដនោះទេ ជាលទ្ធផល ការផ្តន្ទាទោសមានលក្ខណៈបែបធូរលុង។ ក្នុងខែវិច្ឆិកា ឆ្នាំ២០១១ បន្ទាប់ពីមានការទាមទារជាបន្តបន្ទាប់ពីអង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធ រដ្ឋសភា និងព្រឹទ្ធសភាបានអនុម័តច្បាប់ថ្មីមួយ។ ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងបានចាត់ទុកអំពើហិង្សាដោយអាស៊ីដជាបទល្មើស និងផ្តន្ទាទោសជនល្មើសធ្ងន់ធ្ងរជាងបទប្បញ្ញត្តិមុនៗក្នុងក្រមព្រហ្មទណ្ឌ។ ឧទាហរណ៍ ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង នឹងផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររហូតដល់ទៅ ៣០ឆ្នាំ ក្នុងករណីពាក់ព័ន្ធនឹងអំពើហិង្សាដោយអាស៊ីដ។ [30] មិនតែប៉ុណ្ណោះ ច្បាប់នេះបានចែងពីរបបគ្រប់គ្រង ហើយដូច្នេះបានដាក់ឲ្យអ្នកជាប់ពាក់ព័ន្ធនឹងការលក់ និងទិញអាស៊ីដត្រូវមានទំនួលខុសត្រូវព្រហ្មទណ្ឌ ចំពោះការរំលោភបំពានលើលក្ខខណ្ឌនៃអាជ្ញាបណ្ណ និងចំពោះការវាយប្រហារណាដែលកើតមានដោយសារតែការរំលោភបំពានលក្ខខណ្ឌនេះ។[31] របបគ្រប់គ្រងជាក់លាក់ ដែលត្រូវបានគេសន្មត់ថានឹងរួមបញ្ចូលនូវដំណើរការក្នុងការដាក់ពាក្យស្នើសុំ លក្ខខណ្ឌភ្ជាប់ជាមួយការសុំអាជ្ញាបណ្ណ និងតាមដានការអនុវត្តន៍តាមលក្ខខណ្ឌ នឹងមានរូបរាងបន្ទាប់ពីមានការបំពេញបន្ថែមរបស់ក្រសួងមហាផ្ទៃក្នុងអនុក្រឹត្យ[32] ដើម្បីកំណត់នូវរបបគ្រប់គ្រង។ ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង បានផ្តល់ហេដ្ឋារចនាសម្ព័ន្ធការគាំពារជនរងគ្រោះ ដែលជនរងគ្រោះត្រូវការជាចាំបាច់ ក្នុងទម្រង់ជាការព្យាបាល [33] និងការគាំពារផ្នែកច្បាប់[34]

---

[30] សូមអានមាត្រា១៦ - ២៤ នៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង។

[31] សូមអានមាត្រា៥ - ៩, មាត្រា១៤ និងមាត្រា១៧ នៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង។

[32] អនុក្រឹត្យ គឺជាទម្រង់នៃនីតិកម្ម ដែលអនុម័តដោយនាយករដ្ឋមន្ត្រី និងចុះហត្ថលេខាអមដោយរដ្ឋមន្ត្រីដែលពាក់ព័ន្ធ។ ចំពោះឋានានុក្រមផ្នែកច្បាប់ ពាក់ព័ន្ធនឹងទម្រង់នៃច្បាប់ផ្សេងៗ អនុក្រឹត្យគឺនៅក្រោមច្បាប់ ដែលតម្រូវឲ្យចុះព្រះហស្តលេខាដោយព្រះមហាក្សត្រ បន្ទាប់ពីបានលើកយកមកពិភាក្សា និងអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភារួចមក។

[33] សូមអានមាត្រា១០ និងមាត្រា១១ នៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង។

[34] សូមអានមាត្រា១១ នៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង។

និងការស្តារនីតិសម្បទា និងវិធានការការពារ[35] ទោះបីជាទម្រង់ជាក់លាក់នៃហេដ្ឋារចនាសម្ព័ន្ធទាំងនេះនៅមិនទាន់មានភាពច្បាស់លាស់ក៏ដោយ។

ការអនុម័តច្បាប់នេះ នឹងដោះស្រាយចំពោះបទល្មើសដោយអាស៊ីដ និងភាពមិនច្បាស់លាស់នៃបទល្មើសនៃអំពើហិង្សាដោយអាស៊ីដជាពិសេស បើប្រៀបធៀបជាមួយបទល្មើសដទៃទៀត គឺជាការវិវឌ្ឍន៍ដ៏គួរឲ្យស្វាគមន៍នៅកម្ពុជា ហើយដើរតួជាឧបករណ៍ដ៏សំខាន់ក្នុងការទប់ស្កាត់ការវាយប្រហារនាពេលអនាគត ប៉ុន្តែ ក៏មានសារៈសំខាន់ក្នុងការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ និងប្រឆាំងនឹងវប្បធម៌និទណ្ឌភាព។ ប៉ុន្តែ ដើម្បីកាត់បន្ថយបាតុភូតអំពើហិង្សាដោយអាស៊ីដ អ្នកដែលពាក់ព័ន្ធត្រូវតែទទួលខុសត្រូវតាមរយៈការអនុវត្តន៍ច្បាប់ឲ្យមានប្រសិទ្ធភាព បើមិនដូច្នោះទេ វប្បធម៌និទណ្ឌភាពនឹងនៅតែបន្ត ព្រោះថាជនល្មើសអាចគេចពីការជំនុំជម្រះ និងការផ្តន្ទាទោស។ ចាប់តាំងពីច្បាប់នេះចូលជាធរមាន យើងនៅមិនទាន់អាចវាយតម្លៃពីភាពខ្លាំងនៃច្បាប់នេះបាននៅឡើយទេ ដោយសារតែជន-ល្មើសដែលត្រូវទទួលខុសត្រូវចំពោះបទល្មើសដែលកើតឡើង បន្ទាប់ពីមានការអនុម័តច្បាប់នេះមកនៅមិនទាន់ត្រូវបានចាប់ខ្លួន។ ដូច្នេះ របាយការណ៍នេះ ផ្តល់ឱកាសដើម្បីវាយតម្លៃ និងវិភាគដំណើរ-ការយុត្តិធម៌ទាំងមូល ដើម្បីកំណត់ការវិវឌ្ឍន៍ដែលត្រូវការជាចាំបាច់ ដើម្បីធានាការអនុវត្តន៍ច្បាប់គ្រប់-គ្រងអាស៊ីដខ្លាំងឲ្យបានត្រឹមត្រូវ និងដើម្បីបញ្ចប់វដ្តនៃនិទណ្ឌភាព។

[35] សូមអានមាត្រា១២ នៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង។

# ៤. ការដាក់ពាក្យបណ្តឹង

ជាការអនុវត្តជាក់ស្តែង ដោយមិនគិតពីកាតព្វកិច្ចរដ្ឋ ដើម្បីកាត់ទោស និងស្វែងរកយុត្តិធម៌ជូនជនរងគ្រោះដោយអំពើឧក្រិដ្ឋ ការផ្តើមធ្វើការស៊ើបអង្កេតចំពោះករណីវាយប្រហារដោយអាស៊ីដ និងជនល្មើសភាគច្រើន គឺជាញឹកញយពឹងផ្អែកលើការរាយការណ៍បទល្មើសទៅអាជ្ញាធរ។ ប៉ុន្តែ បញ្ហាផ្នែកផ្លូវចិត្តដូចជាការភ័យខ្លាចចំពោះការវាយប្រហារនាពេលអនាគត ជាពិសេស នៅពេលដែលជនល្មើសនៅតែមិនទាន់ត្រូវបានចាប់ខ្លួន និងភាពខ្វះខាតផ្នែកជីវភាព ដូចជា ថ្លៃចំណាយព្យាបាល និងចំណាយផ្នែកច្បាប់ បានរារាំងជនរងគ្រោះមិនឲ្យធ្វើការរាយការណ៍ពីការវាយប្រហារ ហើយនេះជាកត្តាសំខាន់រួមចំណែកក្នុងវប្បធម៌និទណ្ឌភាព ដែលរីករាលដាលយ៉ាងខ្លាំងក្នុងករណីអំពើហិង្សាដោយអាស៊ីដ។ ជំពូកនេះនឹងពិនិត្យមើលបញ្ហាចម្បងៗ ក្នុងដំណាក់កាលរាយការណ៍ ដែលរារាំងមិនឲ្យជនរងគ្រោះដាក់ពាក្យប្តឹង និងជាលទ្ធផលបានរួមចំណែកក្នុងវប្បធម៌និទណ្ឌភាព។

## ភាពងាយរងគ្រោះរបស់ជនរងគ្រោះ

ការរួមចំណែកដ៏សំខាន់មួយក្នុងវប្បធម៌និទណ្ឌភាព ជុំវិញបញ្ហាអំពើហិង្សាដោយអាស៊ីដ គឺពាក់ព័ន្ធនឹងភាពងាយរងគ្រោះផ្នែករាងកាយ ផ្នែកអារម្មណ៍ និងផ្នែកផ្លូវចិត្តរបស់ជនរងគ្រោះបន្ទាប់ពីការវាយប្រហារ ដែលតែងតែបណ្តាលឲ្យជនរងគ្រោះសម្រេចចិត្តមិនដាក់ពាក្យប្តឹង។ ចរិតលក្ខណៈធ្ងន់ធ្ងរនៃរបួសដោយអាស៊ីដ មានន័យថាជនរងគ្រោះត្រូវការការយកចិត្តទុកដាក់ឲ្យបានឆាប់រហ័ស និងជិតដល់ ហើយក៏ដូចជាការព្យាបាលរយៈពេលវែង និងគ្រប់ផ្នែក ដូច្នេះ ជនរងគ្រោះមិនអាចមានលទ្ធភាពដាក់ពាក្យប្តឹង និងបន្តនីតិវិធីផ្នែកច្បាប់ដោយខ្លួនឯងបាននោះទេ។

តាមរយៈបទសម្ភាសន៍ជាមួយជនរងគ្រោះដោយអាស៊ីដ ជនរងគ្រោះភាគច្រើនបង្ហាញពីការភ័យខ្លាចការវាយប្រហារនាពេលអនាគត និងការសងសឹក បើពួកគេនៅតែបន្តនីតិវិធីផ្នែកច្បាប់។ ភាពងាយរងគ្រោះរបស់ជនរងគ្រោះ កាន់តែធ្ងន់ធ្ងរថែមទៀត ដោយហេតុថាជនល្មើសនៅតែមិនទាន់ត្រូវបានចាប់ខ្លួន។ ការស្រាវជ្រាវបានបង្ហាញថា ក្នុងករណីជាច្រើន ជនរងគ្រោះដោយអាស៊ីដត្រូវបានគេបំភ័យ គំរាម ឬបន្លាច ឬបង្ខំមិនឲ្យដាក់ពាក្យប្តឹង។ ការភ័យខ្លាចជនល្មើស គឺជាឧបសគ្គមួយក្នុងការជំរុញឲ្យជនរងគ្រោះដាក់ពាក្យប្តឹង។[36] បងប្អូនពីរនាក់ក្នុងករណីសិក្សា នៃរបាយការណ៍ឆ្នាំ២០១០ ចំណងជើងថា *នាំគ្នាបញ្ឈប់អំពើហិង្សាដោយអាស៊ីដនៅកម្ពុជា* បានទទួលទូរស័ព្ទគំរាមពីជនដែលគិតថាមានការពាក់ព័ន្ធនឹងការវាយប្រហារមកលើពួកគេ ជាលទ្ធផលពួកគេទាំងពីរមិនបានដាក់ពាក្យប្តឹង

[36] មតិរបស់ មន្ត្រីកម្មវិធី របស់ អ.ជ.ជ.ក.អ លោកស្រី ឈុន សុភា ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ ក្នុងសារព័ត៌មាន តៃប៉ាន់ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ២០១០ អាចអានបាន ៖ http://www.taipeitimes.com/News/world/archives/2010/11/18/2003488824/1 ។

ទៅតុលាការព្រោះតែការភ័យខ្លាចការសងសឹក។[37] ការគំរាម និងការបង្ខំមិនឲ្យរាយការណ៍ករណីវាយប្រហារអាចមានមកលើជនរងគ្រោះផ្ទាល់ ឬក្រុមគ្រួសារ។ អវត្តមានវិធានការការពារជនរងគ្រោះ និងសាក្សី បន្តរួមចំណែកធ្វើឲ្យជនរងគ្រោះទោរទន់ទៅតាមការដាក់សម្ពាធរបស់ជនល្មើស ហើយព្រមទទួលយកសំណងជាថ្នូរនឹងការដកពាក្យបណ្ដឹង និងមិនដាក់ពាក្យប្ដឹង។

ភាពងាយរងគ្រោះដែលជនរងគ្រោះបានទទួល កាន់តែធ្ងន់ធ្ងរឡើងដោយសារកង្វះទំនុកចិត្តលើភ្នាក់ងារអនុវត្តច្បាប់ និងប្រព័ន្ធតុលាការ។ ជនរងគ្រោះជាច្រើនដែលយើងបានសម្ភាស គ្មានភាពជឿជាក់លើភ្នាក់ងារអនុវត្តច្បាប់ និងគិតថាប្រព័ន្ធច្បាប់នឹងមិនអាចផ្ដល់ការការពារដ៏សមស្រប ឬផ្ដល់លទ្ធផលដែលមានភាពយុត្តិធម៌សម្រាប់ពួកគេនោះទេ។ ភាពស្មុគស្មាញជុំវិញនីតិវិធីផ្នែកច្បាប់ និងដំណើរការដែលចំណាយពេលយូរ បានបន្តដើរតួជារនាំងមិនឲ្យជនរងគ្រោះបានទទួលយុត្តិធម៌ ដែលជាញឹកញាប់បណ្ដាលមកពីគ្រួសារក្រីក្រ និងជាទូទៅគ្មានចំណេះដឹងពីនីតិវិធីផ្នែកច្បាប់។[38] ដូច្នេះ ពួកគេតែងតែត្រូវបានបញ្ចុះបញ្ចូលពីសំណាក់ជនល្មើសដោយងាយ ថាការដាក់ពាក្យប្ដឹងនេះនឹងគ្មានលទ្ធផលអ្វីទេ ដូច្នេះក៏សម្រេចចិត្តធ្វើការដោះស្រាយក្រៅប្រព័ន្ធតុលាការ។

បញ្ញត្តិក្នុងច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ចំពោះការគាំពារជនរងគ្រោះ ជាពិសេសបញ្ញត្តិការគាំពារផ្នែកច្បាប់សម្រាប់ជនរងគ្រោះដោយអាស៊ីដ ធ្វើឲ្យមានការសង្ឃឹមថា បញ្ហានៃលទ្ធភាពទទួលបានយុត្តិធម៌ដែលបច្ចុប្បន្នដើរតួជួយពង្រឹងនិទណ្ឌភាព ប្រហែលជាអាចដោះស្រាយបានតាមរយៈបទប្បញ្ញត្តិការគាំពារផ្នែកច្បាប់ ទោះបីជាចរិតលក្ខណៈជាក់លាក់នៃការគាំពារនេះមិនទាន់បានដឹងពិតប្រាកដក៏ដោយ ដោយហេតុថាច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងមានភាពមិនច្បាស់លាស់ត្រង់ចំណុចនេះតែម្ដង។ កិច្ចគាំពារជនរងគ្រោះនេះ មានសារៈសំខាន់ណាស់ក្នុងការជួយជនរងគ្រោះដើម្បីទទួលបានយុត្តិធម៌។ ជនរងគ្រោះជាច្រើនដែល ម.ស.ម.ក បាននិយាយជាមួយ បានផ្ដាច់ខ្លួនចេញពីសង្គមបន្ទាប់ពីការវាយប្រហារ តែបន្ទាប់ពីទទួលបានការព្យាបាលលើរូបរាងកាយ និងផ្លូវចិត្តអស់រយៈពេលជាច្រើនឆ្នាំរួចមក ពួកគេមានកម្លាំងដើម្បីពិចារណាពីការដាក់ពាក្យប្ដឹង។ ជាអកុសល អាជ្ញាយុកាលនៃបទល្មើសមួយចំនួនបានផុតកំណត់ ដែលធ្វើឲ្យពួកគាត់រស់នៅដោយគ្មានការដោះស្រាយអ្វីទាំងអស់។ ការគាំពារផ្នែកច្បាប់ដែលចែងដោយច្បាប់ គួរតែអាចជួយឲ្យជនរងគ្រោះបានយល់ពីផលវិបាកនាពេលអនាគត សម្រាប់ការខកខានមិនបានដាក់ពាក្យប្ដឹង។

---

[37] អ.ជ.ជ.ក.អ និង ម.ស.ម.ក កំណត់សម្គាល់លេខ៦ ទំព័រទី៤០។

[38] ដូចខាងលើ ទំព័រទី១៩។

## ការដោះស្រាយក្រៅប្រព័ន្ធតុលាការ

ក្នុងករណីជាច្រើន ការគំរាម ការបង្ខំ និងការបន្លាច បានជោគជ័យក្នុងការបង្ខំឲ្យជនរងគ្រោះធ្វើការដោះស្រាយ ដោយមិនដាក់ពាក្យប្តឹងទៅតុលាការ។ សម្រាប់មនុស្សភាគច្រើន ការដោះស្រាយបែបនេះ ត្រូវបានចាត់ទុកថាអាចទទួលយកបានជាងការជាប់ពាក់ព័ន្ធក្នុងដំណើការនៅតុលាការដែលពួកគេមិនយល់ និងគ្មានការជឿជាក់ថាអាចផ្តល់នូវយុត្តិធម៌បាន។[39] ការដោះស្រាយក្នុងដំណាក់កាលបន្ទាន់បែបនេះ ក៏បានជួយសម្រាលបន្ទុកផ្នែកហិរញ្ញវត្ថុដែលកើនឡើងដោយសារថ្លៃព្យាបាលដល់ជនរងគ្រោះផងដែរ។ ការស្រាវជ្រាវបានបង្ហាញថាថ្លៃចំណាយដែលពាក់ព័ន្ធនឹងការព្យាបាល រួមជាមួយថ្លៃចំណាយដែលពាក់ព័ន្ធនឹងការដាក់ពាក្យប្តឹង ហាក់ដូចជាមានចំនួនច្រើនលើសលុបសម្រាប់ពួកគាត់។ ជនរងគ្រោះដោយអាស៊ីដមួយចំនួនបាននិយាយពីការលក់ដី និងខ្ចីប្រាក់ដើម្បីចំណាយសម្រាប់ការព្យាបាល និង/ឬ ចំណាយចាយវាយនៅក្នុងគ្រួសារ។ ដូច្នេះ ពេលជនល្មើស ឬក្រុមគ្រួសារជនល្មើសបានស្នើទទួលខុសត្រូវចំពោះការចំណាយព្យាបាល និងផ្តល់ប្រាក់សំណងប្រសិនបើជនរងគ្រោះមិនដាក់ពាក្យប្តឹង ភាពទាក់ទាញផ្នែកហិរញ្ញវត្ថុគឺខ្លាំងក្លាដែលមិនអាចបដិសេធនូវសំណើទាំងនោះបាន។

ក្តីសង្ឃឹមមួយចំពោះច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង គឺបញ្ញត្តិដែលពាក់ព័ន្ធនឹងការគាំពារជនរងគ្រោះដោយប្រើប្រាស់ថវិការបស់រដ្ឋ ដូចជា បទប្បញ្ញត្តិនៃការព្យាបាល ការគាំពារផ្នែកច្បាប់ និងការការពារ ការស្តារនីតិសម្បទា និងសមាហរណកម្ម ដែលអាចមានន័យថាភាពខ្វះខាតផ្នែកហិរញ្ញវត្ថុដែលកាលពីមុនបានជួយឲ្យរដ្ឋនៃនិទណ្ឌភាពរីករាលដាល នឹងត្រូវបានកាត់បន្ថយ ហើយអាចឲ្យជនរងគ្រោះអាចដាក់ពាក្យប្តឹងដោយគ្មានឧបសគ្គផ្នែកហិរញ្ញវត្ថុ។ ប៉ុន្តែ ភាពមិនច្បាស់លាស់នៃបញ្ញត្តិក្នុងច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងបានលើកជាសំណួរថា តើបញ្ញត្តិនេះនឹងអាចទទួលបានលទ្ធផលដល់កម្រិតណា ព្រោះច្បាប់នេះខកខានមិនបានចែងលម្អិតពីប្រភេទនៃការព្យាបាលដែលនឹងត្រូវផ្តល់ជូនដល់ជនរងគ្រោះ រយៈពេលដែលការព្យាបាលនេះនឹងត្រូវផ្តល់ជូន ប្រភេទនៃការគាំពារផ្នែកច្បាប់ដែលនឹងត្រូវផ្តល់ជូន និងទម្រង់នៃការការពារ ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មដែលនឹងត្រូវផ្តល់ជូនដោយរដ្ឋ។[40]

---

បន្ទាប់ពីមានការឈ្លោះគ្នាក្នុងខែមិនា ឆ្នាំ១៩៩៨ ស្វាមី របស់ វ៉ាន់ សម្ផស្ស បានប្រើអាស៊ីដដើម្បីវាយប្រហារលើនាងខណៈពេលដែលនាងកំពុងគេងលក់។ ស្វាមីរបស់នាង ជាជាងមាស ហើយអាស៊ីដដែលត្រូវបានយកមកប្រើជាអាស៊ីដសល់ពីការងាររបស់លោក។ នាងពិការភ្នែកទាំងសងខាង ហើយមុខមាត់ និងរូបរាងរបស់នាងពោរ-ពេញទៅដោយស្លាកស្នាម។ ម្តាយរបស់ វ៉ាន់ សម្ផស្ស បានលក់ដីបន្ទាប់ពី វ៉ាន់ សម្ផស្ស ត្រូវរងការវាយប្រហារដើម្បីចំណាយសម្រាប់ការព្យាបាល ប៉ុន្តែ វ៉ាន់ សម្ផស្ស មិនស្នាក់នៅមន្ទីរពេទ្យយូរថ្ងៃពេកនោះទេ ដោយសារតែ

[39] ដូចខាងលើ ទំព័រទី២៣។

[40] សូមអានមាត្រា១០ - ១៣ នៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ឆ្នាំ២០១១។

នាងដឹងថានាងត្រូវចំណាយប្រាក់ជាច្រើន ហើយពួកគេត្រូវការប្រាក់។ នាងត្រូវបង្ខំចិត្តបោះបង់កូនស្រីទីពីររបស់នាង ដោយសារតែនាងគ្មានលទ្ធភាពចិញ្ចឹម។ បន្ទាប់ពីការវាយប្រហារ ស្វាមីរបស់ វ៉ាន់ សម្ផស្ស បានគេចខ្លួនទៅនៅក្រៅប្រទេស។ គាត់បានបញ្ជូនបងប្អូនជីដូនមួយដើម្បីមកចរចាជាមួយ វ៉ាន់ សម្ផស្ស។ បងប្អូនជីដូនមួយនោះបានស្នើផ្តល់ទឹកប្រាក់ចំនួនប្រហែល ២០០-៣០០ដុល្លារ ជាសំណង រួមជាមួយនឹងការបង់ប្រាក់សំណងប្រចាំខែជាទៀងទាត់ឲ្យនាងពេញមួយជីវិត។ គេប្រាប់នាងថា ប្រសិនបើនាងមិនព្រមទទួលទេនោះ នាងនឹងមិនបានអ្វីទាំងអស់ ព្រោះនាងគ្មានលទ្ធភាពឈ្នះរឿងក្តីនៅតុលាការនោះទេ។ ប្រឈមនឹងការគំរាម និងការបន្លាចបែបនេះ វ៉ាន់ សម្ផស្ស សម្រេចទទួលយកការដោះស្រាយ និងទទួលយកលិខិតដែលមានស្នាមមេដៃស្វាមីរបស់នាង ដើម្បីធានាការផ្តល់ប្រាក់សំណងពេញមួយជីវិត។ ប៉ុន្តែ នាងនិយាយថាប្រាក់សំណងនេះ គឺមិនទៀងទាត់ ពេលខ្លះនាងបានទទួល ពេលខ្លះក៏មិនបានទទួល។

## ទំនាក់ទំនងរវាងជនរងគ្រោះ និងជនល្មើស

បញ្ហាចុងក្រោយ និងពិបាកបំផុតសម្រាប់ធ្វើការពិចារណា នៅពេលដាក់ពាក្យប្តឹងពាក់ព័ន្ធនឹងអំពើហិង្សាដោយអាស៊ីដ គឺទំនាក់ទំនងរវាងជនរងគ្រោះ និងជនល្មើស។ ដោយហេតុថា ការវាយ-ប្រហារដោយអាស៊ីដភាគច្រើន គឺត្រូវបានធ្វើឡើងរវាងស្វាមីភរិយា ឬគូសង្សារ ដូច្នេះទំនាក់ទំនងរវាងជនរងគ្រោះ និងជនល្មើស ជាញឹកញាប់មានសារៈសំខាន់ចំពោះការសម្រេចចិត្តរបស់ជនរងគ្រោះថាគួរដាក់ពាក្យប្តឹង ឬមិនគួរ។ តាមរយៈការស្រាវជ្រាវ យើងរកឃើញថាជនរងគ្រោះតែងតែពឹងពាក់លើជនល្មើសទាំងផ្នែកអារម្មណ៍ ផ្នែកហិរញ្ញវត្ថុ និងពេលខ្លះទៀតគឺផ្នែកកាយសម្បទា ដែលអាចប៉ះពាល់ដល់ការសម្រេចចិត្តមិនដាក់ពាក្យប្តឹង។[41] សុខ វិចិត្រ ត្រូវបានភរិយារបស់ខ្លួនវាយប្រហារក្នុងឆ្នាំ២០០៩ បន្ទាប់ពីការឈ្លោះប្រកែកគ្នា ដែលក្នុងពេលនោះលោកបាននិយាយទាំងខឹងសម្បារទៅកាន់ភរិយាថា លោកនឹងចាកចេញពីផ្ទះ ទោះបីជាការពិតលោកគ្មានបំណងនឹងធ្វើបែបនេះនោះទេ។ បន្ទាប់ពីការវាយប្រហារ អាជ្ញាធរមានបំណងចង់ចាប់ឃាត់ខ្លួនភរិយារបស់លោក ប៉ុន្តែ សុខ វិចិត្រ បានជំទាស់មិនឲ្យចាប់ខ្លួន ដោយនិយាយថាប្រសិនបើចាប់ខ្លួនភរិយាលោក នោះនឹងគ្មាននរណាមើលថែទាំលោក និងកូនទាំង៧នោះទេ។ ភរិយារបស់លោកក្លាយទៅជាអ្នករកស៊ីចិញ្ចឹមគ្រួសារ និងបានមើលថែទាំរូបលោកបន្ទាប់ពីការវាយប្រហារ។

កែវ មេត្តា និងភរិយាតែងតែឈ្លោះគ្នាជាប្រចាំ ព្រោះថាគាត់មានទំនាក់ទំនងជាមួយនារីជាច្រើន។ ថ្ងៃមួយ ក្នុងឆ្នាំ២០០៩ ភរិយារបស់គាត់បានដឹងថា កែវ មេត្តា មិនបានទៅធ្វើការនោះទេ តែបែរជាទៅជួបមិត្តស្រីរបស់គាត់ និងស្នាក់នៅជាមួយនាងអស់មួយយប់។ នៅពេលត្រលប់មកដល់ផ្ទះវិញ ភរិយារបស់គាត់បានជះទឹកអាស៊ីដមកលើគាត់។ បច្ចុប្បន្នគាត់ត្រូវពិការភ្នែកទាំងសងខាង។ គាត់បាននិយាយថា គាត់មិនបានដាក់ពាក្យប្តឹងនោះទេ ដោយសារតែគាត់មានការព្រួយបារម្ភថានឹងមានអ្វីកើតឡើងចំពោះកូនស្រីទាំងបី ប្រសិនបើភរិយារបស់លោកនៅក្នុង

[41] អ.ជ.ជ.ក.អ និង ម.ស.ម.ក ឆ្នាំ២០១០ របាយការណ៍ "យើងនាំគ្នាបញ្ឈប់អំពើហិង្សាដោយអាស៊ីដ នៅកម្ពុជា" ទំព័រទី២៣។

ពន្ធនាគារ។ លោកនិយាយថា លោកនឹងចូលពន្ធនាគារជំនួសភរិយា ហើយទុកឲ្យភរិយារបស់លោកមើលថែទាំកូនៗរបស់លោកជំនួសវិញ។ កែវ មេត្តា ធ្លាប់ធ្វើជាមន្ត្រីនគរបាល និងធ្លាប់អមគណៈប្រតិភូ ប៉ុន្តែបច្ចុប្បន្នលោកបាត់បង់អ្វីគ្រប់យ៉ាង រួមទាំងឋានៈរបស់លោកផងដែរ។ លោកមានភាពភ័យខ្លាចតែម្យ៉ាង គឺខ្លាចថាភរិយារបស់លោកនឹងបោះបង់លោកចោល ហើយរកស្វាមីថ្មីជំនួស។

---

ក្នុងកាលៈទេសៈដែលជនរងគ្រោះពឹងផ្អែកលើជនល្មើស គឺជាករណីពិសេសមួយនៅជុំវិញករណីអំពើហិង្សាដោយអាស៊ីដ និងជាករណីពិបាកដោះស្រាយបំផុត។ ប៉ុន្តែ ម.ស.ម.ក សង្ឃឹមថាឧបសគ្គក្នុងស្ថានភាពបែបនេះ នឹងអាចដោះស្រាយបានតាមរយៈច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង។ ក្នុងករណីទាំងនេះហើយ ដែលបញ្ញត្តិនៃការគាំពារជនរងគ្រោះក្នុងច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង កាន់តែមានសារៈសំខាន់ថែមទៀត ដោយហេតុថាជនរងគ្រោះប្រហែលជាលែងពឹងផ្អែកលើជនល្មើសទាំងផ្នែកហិរញ្ញវត្ថុ ឬផ្នែកកាយសម្បទា ដែលពីមុនមកជាឧបសគ្គសម្រាប់ពួកគេក្នុងការដាក់ពាក្យប្តឹង។ ការធានាឲ្យមានប្រព័ន្ធគាំពារ និងការផ្តល់សំណងដ៏ឯករាជ្យមួយនឹងអាចជួយឲ្យជនរងគ្រោះហ៊ានដាក់ពាក្យប្តឹងដោយគ្មានការភ័យខ្លាចពីឧបសគ្គទាំងនេះ។

# ៥. ការស៊ើបអង្កេត

ការស៊ើបអង្កេតដ៏សមស្រប និងទាន់ពេលវេលា ក្នុងករណីអំពើហិង្សាដោយអាស៊ីដ គឺមានសារៈសំខាន់ក្នុងការធានាឲ្យមានការផ្តន្ទាទោស ហើយជាលទ្ធផលយុត្តិធម៌នឹងត្រូវបានផ្តល់ជូនទៅជនរងគ្រោះ។ ដើម្បីឲ្យករណីនេះអាចមានភាពជោគជ័យចំពោះជនល្មើស គឺតម្រូវឲ្យមានការស៊ើបអង្កេតឲ្យបានម៉ត់ចត់ ការប្រមូលទិន្នន័យឲ្យបានត្រឹមត្រូវ ដែលមានការពាក់ព័ន្ធពីភាគីផ្សេងៗក្នុងដំណាក់កាលស៊ើបអង្កេត ដូចជា មន្ត្រីនគរបាល ព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេត សហការណ៍គ្នាដើម្បីធានារកឲ្យឃើញយុត្តិធម៌។ ជំពូកនេះនឹងពិនិត្យមើលលើឧបសគ្គ និងបរាជ័យក្នុងដំណើរការយុត្តិធម៌ដែលកើតឡើងក្នុងដំណាក់កាលស៊ើបអង្កេត។

## ភាពអសកម្មក្នុងការស៊ើបអង្កេត

ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ក្រមនីតិវិធីព្រហ្មទណ្ឌ) បានចែងពីធន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញា ក្នុងការចាប់ផ្តើមនីតិវិធីផ្នែកព្រហ្មទណ្ឌ។ ដូច្នេះ ទស្សនៈចំពោះអំពើហិង្សាដោយអាស៊ីដអាចមានឥទ្ធិពលក្នុងដំណើរការស៊ើបអង្កេតករណីបទល្មើសដោយអាស៊ីដ។ បន្ទាប់ពីមានការវាយប្រហារលើកទីពីរក្នុងឆ្នាំ២០១២ ដែលបណ្តាលឲ្យបុរសម្នាក់អាយុ ៤២ឆ្នាំត្រូវស្លាប់ និងស្ត្រីម្នាក់រងរបួសជាទម្ងន់ក្នុងខេត្តកំពង់ចាម ប្រធានភូមិ លោក សៀង ហេង ត្រូវបានរាយការណ៍ថាលោកបាននិយាយថាបុរសម្នាក់នេះគឺល្បីខាងចូលចិត្តវាយតប់ភរិយា ហើយប្រសិនបើភរិយារបស់បុរសនោះមានពាក់ព័ន្ធក្នុងការវាយប្រហារនេះ *"ប្រហែលដោយសារនាងមិនអាចទ្រាំចំពោះការរំលោភបំពានទាំងផ្នែករូបរាងកាយ និងផ្នែកផ្លូវចិត្តបន្តទៀត"* ។[42] ការនិយាយបែបបញ្ជាក់ន័យរបស់អាជ្ញាធរមូលដ្ឋាន ថា ការវាយប្រហារនេះមានហេតុផល ជាឧទាហរណ៍មួយឆ្លុះបញ្ចាំងពីទស្សនៈក្នុងសង្គមរបស់អាជ្ញាធរដែលធ្វើឲ្យមានការពិបាកក្នុងការស៊ើបអង្កេតដ៏ម៉ត់ចត់មួយចំពោះអំពើហិង្សាដោយអាស៊ីដ។[43] ជនរងគ្រោះមួយចំនួន ដែលយើងបានជួបនិយាយជាមួយ លើកឡើងថាស្ថានភាពគ្រួសារក្រីក្រ អាចរួមចំណែក បណ្តាលឲ្យមានការខ្វះខាតការស៊ើបអង្កេតដ៏ត្រឹមត្រូវមួយក្នុងករណីការវាយប្រហារដោយអាស៊ីដទាំងនេះ។

---

នាង នេត្រា មិនបានដាក់ពាក្យប្តឹងទៅកាន់អាជ្ញាធរ ឬតុលាការនោះទេ បន្ទាប់ពីរងការវាយប្រហារក្នុងផ្ទះរបស់លោក ពេលពាក់កណ្តាលអាធ្រាត ក្នុងឆ្នាំ២០០៣។ លោកសង្ស័យថាជនល្មើស ជាបុរសម្នាក់ក្នុងភូមិរបស់លោក ដែលច្រណែនដោយសារតែ នាង នេត្រា មានមិត្តស្រី។ ប៉ុន្តែ នាង នេត្រា មិនបានដឹងប្រាកដនោះទេថា បុគ្គល

[42] សារព័ត៌មាន ឌឹ ខែមបូឌា ដេលី ថ្ងៃទី១០-១១ ខែមិនា ឆ្នាំ២០១២ "មនុស្សពីរនាក់រងការវាយប្រហារដោយអាស៊ីដ ភរិយាគឺជាជនសង្ស័យសំខាន់ម្នាក់" ។

[43] អ.ជ.ជ.ក.អ និង ម.ស.ម.ក កំណត់សម្គាល់លេខ៦ ទំព័រទី២៥។

ដែលលោកសង្ស័យពិតជាជនល្មើសមែនឬក៏យ៉ាងណា ដោយភ័យខ្លាចថាលោកដាក់ពាក្យប្តឹងលើមនុស្សខុស។ លោកបានកត់សម្គាល់ថា អាជ្ញាធរមិនបានយកចិត្តទុកដាក់ចំពោះករណីរបស់លោកទេ។ មន្ត្រីនគរបាលមិនបានធ្វើការស៊ើបអង្កេតណាមួយសោះ។ លោកគិតថា ដោយសារតែលោកមានជីវភាពក្រីក្រ ទើបអាជ្ញាធរមិនចាប់អារម្មណ៍ចំពោះករណីនេះ។

នាង នេត្រា ចង់ឲ្យរដ្ឋាភិបាលជំរុញ និងគាំទ្រដល់ការស៊ើបអង្កេតក្នុងករណីអំពើហិង្សាដោយអាស៊ីដ។ លោកចង់ឃើញជនល្មើសត្រូវបានចាប់ខ្លួន និងនាំយកមកកាត់ទោស។

---

មានករណីមួយចំនួនតូចប៉ុណ្ណោះ ដែលសមត្ថកិច្ចឆ្លើយតបយ៉ាងឆាប់រហ័សចំពោះការស៊ើប-អង្កេតករណីបទល្មើសអាស៊ីដ និងការចាប់ខ្លួនជនល្មើស ឬក៏បានឈានទៅរកការឃាត់ខ្លួនជនដែលត្រូវបានអះអាងថាជាជនល្មើស។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ ពីរបីម៉ោងក្រោយបន្ទាប់ពីស្ត្រីពីរនាក់ត្រូវរងការវាយប្រហារដោយអាស៊ីដចំនួនកន្លះលីត្រ ក្នុងពេលពួកគេធ្វើដំណើរត្រលប់ទៅផ្ទះ ដោយពួកគេគិតមូលហេតុនៃការវាយប្រហារនេះ កើតមានដោយសារជម្លោះតូចមួយនៅកន្លែងធ្វើការ មន្ត្រីនគរបាលខណ្ឌមានជ័យ រាជធានីភ្នំពេញ បានចាប់ខ្លួនជនសង្ស័យចំនួន ៣នាក់ ដែលត្រូវផ្តន្ទាទោសដោយតុលាការរាជធានីភ្នំពេញរយៈពេល ២ថ្ងៃបន្ទាប់មកទៀត។[44] មានករណីថ្មីមួយទៀត ដែលមន្ត្រីនគរបាល បានឃាត់ខ្លួនជនដែលត្រូវអះអាងថាជាជនល្មើសក្នុងករណីវាយប្រហារដោយអាស៊ីដរយៈពេលបីឆ្នាំក្រោយពីករណីនោះកើតឡើង។ ក្នុងខែមិថុនា ឆ្នាំ២០១១ មានការរាយការណ៍ថា ស្ត្រីម្នាក់ ឈ្មោះ យឹម ម៉ាលី អាយុ ៣៦ឆ្នាំ ត្រូវបានចាប់ឃាត់ខ្លួនដោយមន្ត្រីនគរបាលរាជធានីភ្នំពេញដោយមានការសង្ស័យថាបានប្រព្រឹត្តអំពើវាយប្រហារមកលើស្ត្រីម្នាក់ក្នុងឆ្នាំ២០០៨។ យឹម ម៉ាលី ត្រូវគេគិតថាបានគេចទៅប្រទេសវៀតណាមក្នុងឆ្នាំ២០០៨ បន្ទាប់ពីការវាយប្រហារ។[45]

ខណៈពេលដែលការចាប់ឃាត់ខ្លួនបុគ្គលបីរូបបានយ៉ាងឆាប់រហ័ស ក្នុងខែមករា ឆ្នាំ២០១១ បានដើរតួដូចជាការព្រមានដល់ជនល្មើសនៃអំពើហិង្សាដោយអាស៊ីដ ថាពួកគេនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ករណីនេះមិនបានឆ្លុះបញ្ចាំងពីរយៈពេលនៃដំណើរការទូទៅ ដែលជនរងគ្រោះត្រូវប្រឈម មុននឹងការស៊ើបអង្កេតត្រូវបញ្ចប់ និងមានការចាប់ខ្លួនជនល្មើសនោះទេ។ សូម្បីតែនៅពេលការស៊ើបអង្កេតត្រូវបានធ្វើឡើង ជាទូទៅមន្ត្រីនគរបាលបានបញ្ជាក់ថាពួកគេមិនអាចចាប់ខ្លួនជនល្មើសបាន ព្រោះមិនទាន់ទទួលបានដីកាចាប់ខ្លួន។ ចំពោះអំពើហិង្សាដោយអាស៊ីដ ក្នុងខែមករា ឆ្នាំ២០១២ ចាន់ សារុធ ស្នងការនគរបាលរង ខណ្ឌឫស្សីកែវ និយាយនៅខែមិនា ឆ្នាំ២០១២ ថាលោក

[44] សារព័ត៌មាន ឌឹ ខែមបូឌា ដេលី ថ្ងៃទី២០ ខែមករា ឆ្នាំ២០១១ "មនុស្ស៣នាក់ ត្រូវបានចាប់ខ្លួនក្នុងករណីអំពើវាយប្រហារដោយអាស៊ីដក្នុងឆ្នាំ២០១១", សារ-ព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្តិ៍ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ "តុលាការចោទប្រកាន់មនុស្ស ៣នាក់ឲ្យឲ្យជាប់ទោសក្នុងករណីអំពើហិង្សាដោយអាស៊ីដ" និងសារ-ព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្តិ៍ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ "មនុស្ស ៣នាក់ត្រូវបានចោទប្រកាន់ក្នុងរឿងករណីអំពើហិង្សាដោយអាស៊ីដ" ។

[45] សារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្តិ៍ ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១ "ស្ត្រីត្រូវបានចាប់ខ្លួនក្នុងរយៈពេល ៣ឆ្នាំ ក្រោយការវាយប្រហារ" ។

នៅរង់ចាំឲ្យមន្ត្រីតុលាការចេញដីកាចាប់ខ្លួនជនសង្ស័យ ដែលលោកបានបញ្ជូនឯកសារពាក់ព័ន្ធចាំបាច់ដែលតម្រូវឲ្យមានរួចរាល់ហើយ។[46] សូម្បីតែនៅពេលដែលមានដីកាចាប់ខ្លួនចេញដោយមន្ត្រីតុលាការបន្ទាប់ពីការវិនិច្ឆ័យទោស តែនៅមានការពន្យារពេលដើម្បីទទួលឯកសារសំខាន់ៗ ក្នុងការចាប់ជនល្មើសដែលបានវិនិច្ឆ័យទោសរួចហើយ (សូមអានជំពូកទី៦ សម្រាប់ព័ត៌មានលម្អិត )។[47]

មានចំណុចជាច្រើនទៀតដែលអនុវត្ត ដើម្បីធានាថាការស៊ើបអង្កេតនឹងត្រូវធ្វើឡើងដោយមានប្រសិទ្ធភាព និងពេញលេញ ពីសំណាក់ភាគីពាក់ព័ន្ធក្នុងដំណាក់កាលស៊ើបអង្កេត ចាប់ពីមន្ត្រីនគរបាល ដល់ ចៅក្រមស៊ើបសួរ។ រដ្ឋាភិបាល គួរតែពិចារណាបញ្ញត្តិដាក់លាក់ក្នុងច្បាប់ ដើម្បីឲ្យមានការស៊ើបអង្កេតទាន់ពេល និងថែមទាំងអាចឲ្យអ្នកស៊ើបអង្កេតទាំងនោះទទួលខុសត្រូវចំពោះការខកខានរបស់ពួកគេ។ ក្នុងបរិបទនៃបទល្មើសដោយអាស៊ីដ មានឧទាហរណ៍នៃយុត្តាធិការមួយចំនួន ដែលច្បាប់ចែងពីការស៊ើបអង្កេតលើករណីវាយប្រហារដោយអាស៊ីដជាចាំបាច់។ ឧទាហរណ៍ នៅប្រទេសបង់ក្លាដែស ច្បាប់គ្រប់គ្រងអាស៊ីដ បានចែងជាពិសេសថា រាល់ការស៊ើបអង្កេតលើករណីបទល្មើសដោយអាស៊ីដត្រូវតែបញ្ចប់ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីទទួលដំណឹងថាមានករណីបទល្មើសកើតឡើង ឬត្រូវបានបង្គាប់ដោយចៅក្រម។[48] បន្ថែមពីលើនោះ ថែមទាំងមានការដាក់ទណ្ឌកម្មចំពោះអ្នកដែលធ្វើសកម្មភាពមិនអំណោយផល ដែលប៉ះពាល់ដល់ការស៊ើបអង្កេត ហើយច្បាប់ចែងថា នឹងត្រូវចាត់វិធានការផ្នែកច្បាប់ចំពោះមន្ត្រីផ្នែកស៊ើបអង្កេតណាដែលប្រមូលភស្តុតាង ឬរបាយការណ៍សាក្សី ប្រសិនបើ *"ដើម្បីជួយនរណាម្នាក់គេចផុតពីការទទួលខុសត្រូវចំពោះបទល្មើសដែលពួកគេបានប្រព្រឹត្ត មន្ត្រីនោះមិនបានប្រមូល ឬពិនិត្យនូវភស្តុតាងដែលអាចប្រើប្រាស់បាន ឬឲ្យជនល្មើសធ្វើជាសាក្សី ឬក៏ជៀសវាងមិនសាកសួរសាក្សីសំខាន់ៗ ក្នុងពេលធ្វើរបាយការណ៍"*។[49] រដ្ឋាភិបាលគួរតែពិចារណាធ្វើវិសោធនកម្មច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ដើម្បីបញ្ចូលនូវបញ្ញត្តិទាំងឡាយដើម្បីលុបបំបាត់ ភាពអសកម្មដែលមានក្នុងដំណាក់កាលស៊ើបអង្កេតនៃនីតិវិធីព្រហ្មទណ្ឌ ដូចជាចែងថា ពាក្យបណ្តឹងប្រឆាំងនឹងមន្ត្រីនគរបាលអាចនឹងត្រូវធ្វើឡើង ឬក៏អ្នកដទៃដែលពាក់ព័ន្ធនឹងករណីទាំងនេះ នៅពេលដែលមានការធ្វេសប្រហែសក្នុងតួនាទីរបស់ពួកគេក្នុងការធានាឲ្យមានការស៊ើបអង្កេតឲ្យបានសមស្រប និងពេញលេញ។

[46] សារព័ត៌មាន ឌឺ ភ្នំពេញ ប៉ុស្តិ៍ ថ្ងៃទី២៨ ខែមិនា ឆ្នាំ២០១២ "ជនរងគ្រោះដោយអាស៊ីដស្វែងរកការជួយសង្គ្រោះ" ។

[47] ក្នុងករណី ការវាយប្រហារកាលពីខែឧសភា ឆ្នាំ២០០៨ មកលើ លោកស្រី យ៉ា សុខនីម បន្ទាប់ពីមានចោទប្រកាន់អតីតមេបញ្ជាការនគរបាល លោកស្រី ជា រដ្ឋា, មាស ម៉ៅ និងសៀក ចាន់ឌី ថាបានប្រព្រឹត្តអំពើវាយប្រហារ ស្នងការនគរបាលរាជធានីភ្នំពេញ បានបញ្ជាក់ថា គាត់មិនអាចចាប់ខ្លួនជនល្មើសដែលបានធ្វើការវាយប្រហារនេះទេ ដោយសារតែផ្នែករបស់គាត់មិនទាន់បានទទួលដីកាចាប់ខ្លួននៅឡើយ។

[48] ច្បាប់គ្រប់គ្រងបទល្មើសដោយអាស៊ីដ នៃប្រទេសបង់ក្លាដែស មាត្រា១១។

[49] ច្បាប់គ្រប់គ្រងបទល្មើសដោយអាស៊ីដ នៃប្រទេសបង់ក្លាដែស មាត្រា១៣។

## កង្វះខាតការបណ្ដុះបណ្ដាលដ៏សមស្រប

មានការលើកឡើងពីកង្វះខាតការបណ្ដុះបណ្ដាលដ៏សមស្រប សម្រាប់មន្ត្រីពាក់ព័ន្ធដែលអាចមានផលប៉ះពាល់ចំពោះលទ្ធភាពរបស់នគរបាលក្នុងការប្រមូលទិន្នន័យ និងភស្តុតាងដែលចាំបាច់សម្រាប់គោលបំណងនៃការផ្ដន្ទាទោស។ ការស្រាវជ្រាវបានបង្ហាញថាមន្ត្រីនគរបាល ពេលខ្លះបានដាក់បន្ទុកមកលើជនរងគ្រោះ ក្នុងការផ្ដល់ភស្តុតាងចាំបាច់។ ក្នុងករណី រស់ រំដួល ដែលត្រូវបងថ្លៃប្រុសរបស់នាងវាយប្រហារ ក្នុងឆ្នាំ២០០៩ នាងបានចង្អុលជនល្មើសក្នុងមន្ទីរពេទ្យ នៅចំពោះមុខមន្ត្រីនគរបាល និងចោទប្រកាន់ថាជនម្នាក់នោះបានវាយប្រហារមកលើនាង ។ ប៉ុន្តែ មន្ត្រីនគរបាលនោះបានបដិសេធមិនចាប់ខ្លួនជនល្មើសដោយសំអាងថាគ្មានភស្តុតាងគ្រប់គ្រាន់។ ជំនួសឲ្យការចាប់ខ្លួនជនដែលត្រូវបានគេអះអាងថាជាជនល្មើស និងនាំខ្លួនមកប៉ុស្ដិ៍នគរបាលដើម្បីសាកសួរ មន្ត្រីនគរបាលរូបនេះបែរជាប្រាប់ រស់ រំដួល ឲ្យយកជបទទេមួយទៅប៉ុស្ដិ៍នគរបាលដើម្បីធ្វើជាភស្តុតាងនៃការវាយប្រហារ។ [50]

កង្វះខាតការបណ្ដុះបណ្ដាល ដែលធ្វើឲ្យការស៊ើបអង្កេតមានលក្ខណៈមិនគ្រប់គ្រាន់ធ្វើឲ្យជនរងគ្រោះមួយចំនួនត្រូវចំណាយប្រាក់ផ្ទាល់ខ្លួន ដើម្បីប្រមូលភស្តុតាងចាំបាច់ក្នុងការទាមទារឲ្យមានការផ្ដន្ទាទោស។ ជនរងគ្រោះម្នាក់ ឈ្មោះ វ៉ាន់ សុភា បាននិយាយជាមួយ ម.ស.ម.ក ប្រាប់ពីវិធីដែលបងប្រុសនាងត្រូវខ្ចីប្រាក់ ដើម្បីចំណាយលើកោសល្យវិច្ច័យបន្ទាប់ពីរងការវាយប្រហារក្នុងឆ្នាំ២០០០ ដែលបណ្ដាលឲ្យនាងត្រូវពិការភ្នែកទាំងសងខាង។ បន្ទាប់ពីបានកោសល្យវិច្ច័យរួចមក វ៉ាន់ សុភា និងបងប្រុសរបស់នាងបានប្រគល់ភស្តុតាងទៅមន្ត្រីនគរបាល ក៏ប៉ុន្តែបែរជាត្រូវបានប្រាប់ថា ភស្តុតាងនេះមិនគ្រប់គ្រាន់ក្នុងការដាក់ពាក្យប្ដឹង។ ទោះបីជាយ៉ាងនេះក្ដី មន្ត្រីនគរបាលមិនបានធ្វើការស៊ើបអង្កេតដោយខ្លួនឯងនោះទេ។ នាងគិតថាមន្ត្រីនគរបាលទទួលប្រាក់សំណូកពីជនល្មើសដើម្បីមិនបន្តដំណើរការដាក់ពាក្យប្ដឹង។

## កង្វះខាតការសហការពីសាក្សីសំខាន់

កង្វះខាតការសហការពីសាក្សីសំខាន់ៗ ជាបញ្ហាមួយទៀតដែលបង្កឧបសគ្គដល់ការស៊ើបអង្កេតដ៏មានប្រសិទ្ធភាពមួយ។ ដូចក្នុងករណីជនរងគ្រោះដែរ ការភ័យខ្លាចចំពោះការសងសឹក ការបន្លាច ការគំរាមកំហែង ការសម្លុតបំភ័យ ទាំងអស់នេះបានរួមចំណែកក្នុងការបិទមាត់សាក្សី ហើយដូច្នេះធ្វើឲ្យមិនអាចមានការបំភ្លឺពីសាក្សីដែលឃើញផ្ទាល់ភ្នែក ដែលជាកត្តាដ៏សំខាន់មួយនាំឲ្យមានការផ្ដន្ទាទោស។ ក្នុងករណីរបស់ រស់ រំដួល មានសាក្សីមួយចំនួន រាប់បញ្ចូលទាំងប្អូនស្រីរបស់នាងផងដែរ ប៉ុន្តែ ពួកគេទាំងអស់មិនហ៊ានបំភ្លឺក្នុងករណីនេះទេ ដោយសារតែភ័យខ្លាចការសងសឹក។ សាក្សីទាំង

[50] មជ្ឈមណ្ឌល អារ៉ែន ពិភពលោកសម្រាប់ស្ត្រី និងយុត្តិធម៌ នៃសាលាច្បាប់ខរណែល ឆ្នាំ២០១១ "លុបបំបាត់អំពើហិង្សាដោយអាស៊ីដនៅប្រទេស បង់ក្លាដែស ឥណ្ឌា និងកម្ពុជា" កំណត់សម្គាល់លេខ ៧ ទំព័រទី៣៩។

នោះក៏មានមន្ត្រីនគរបាលនៅក្រៅម៉ោងការងារម្នាក់ និងភរិយារបស់លោក ដែលរស់នៅជាប់នឹងកន្លែងកើតហេតុ។ មន្ត្រីនគរបាលម្នាក់នេះ ត្រូវបានរាយការណ៍ថាបានទូរស័ព្ទទៅសុំជំនួយដើម្បីព្យាយាម និងចាប់ជនល្មើសបន្ទាប់ពីការវាយប្រហារ ប៉ុន្តែមន្ត្រីនគរបាលទាំងនោះមកដល់កន្លែងកើតហេតុយឺតពេលរួចជនល្មើសគេចខ្លួនបាត់។[51] អវត្តមានប្រព័ន្ធការពារសាក្សីឲ្យបានត្រឹមត្រូវ ដើរតួយ៉ាងសំខាន់ក្នុងការធ្វើឲ្យសាក្សីសំខាន់ដែលមិនហ៊ាននិយាយ អាចធ្វើការបំភ្លឺ និងបង្ហាញជាភស្តុតាងក្នុងការផ្តន្ទាទោសមកលើជនល្មើសនៃអំពើហិង្សាដោយអាស៊ីដ។

## អំពើពុករលួយ

បញ្ហាអំពើពុករលួយ ជាពិសេសក្នុងពេលដែលមន្ត្រីនគរបាលទទួលយកប្រាក់សគុណដើម្បីមិនបន្តនីតិវិធីផ្នែកច្បាប់ ត្រូវបានលើកយកមកនិយាយដោយជនរងគ្រោះមួយចំនួនក្នុងអំឡុងពេលនៃការស្រាវជ្រាវ។ ក្នុងករណីមួយចំនួន ជនរងគ្រោះបាននិយាយអំពីបរាជ័យក្នុងតួនាទីរបស់អាជ្ញាធរដើម្បីស៊ើបអង្កេតករណីបទល្មើសដោយអាស៊ីដ និងចាប់ខ្លួនជនល្មើស តែបែរជាជួយសម្របសម្រួលឲ្យមានការដោះស្រាយក្រៅតុលាការ។ ជនរងគ្រោះមួយចំនួន ដែលដាក់ពាក្យប្តឹង បាននិយាយថាដំណើរការស៊ើបអង្កេតដែលនឹងត្រូវធ្វើឡើង គឺមានភាពយឺតយ៉ាវដោយសារតែគ្មានការផ្តល់សំណូកឲ្យមន្ត្រីនគរ- បាល។ ឧទាហរណ៍ រស់ រំដួល មិនសង្ឃឹមថាប្រព័ន្ធតុលាការនឹងអាចរកយុត្តិធម៌ឲ្យនាងក្នុងការវាយប្រហារដែលនាងបានជួបប្រទះ កាលពីឆ្នាំ២០០៩ នោះទេ ព្រោះថានាងគ្មានប្រាក់គ្រប់គ្រាន់ក្នុងការចំណាយឲ្យមន្ត្រីនគរបាល។[52]

---

*“នៅពេលដែលនគរបាលបានឮពីករណីវាយប្រហារដោយអាស៊ីដ ពួកគេនឹងចាត់វិធានការ ប៉ុន្តែគឺផ្អែកទៅលើករណីនីមួយៗ...ប្រសិនបើគ្មានផលប្រយោជន៍សម្រាប់គេនោះទេ គេនឹងមិនធ្វើការស៊ើបអង្កេតឡើយ។ នេះជាបញ្ហានៃអំពើពុករលួយក្នុងករណីទាំងអស់។ ប្រសិនបើអ្នកគ្មានប្រាក់ នោះមន្ត្រីនគរបាលនឹងដាក់វានៅខាងក្រោមបង្អស់នៃគំនរឯកសារ” ។[53]*

---

វ៉ាន់ សុភា ដែលបានបាត់បង់ភ្នែកទាំងពីររបស់នាង និងមានបញ្ហាត្រចៀក ព្រោះតែការវាយប្រហារក្នុងឆ្នាំ២០០០ ដោយភរិយារបស់អ្នកជិតខាង ដែលបានយល់ច្រឡំថានាងមានទំនាក់ទំនងនឹងស្វាមីរបស់គាត់ បាននិយាយប្រាប់ ម.ស.ម.ក ថាជំនួសឲ្យការស៊ើបអង្កេតករណីវាយប្រហារឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលា មន្ត្រីនគរបាលក្នុងខេត្តបាត់ដំបងបែរជាជួយសម្រួលការបង់ប្រាក់សំណង

[51] សូមអានករណីសិក្សា ក្នុងរបាយការណ៍ របស់ អ.ជ.ជ.ក.អ និង ម.ស.ម.ក កំណត់សម្គាល់លេខ ៦ ទំព័រទី៣៩។

[52] មជ្ឈមណ្ឌល អារ៉ែន ពិភពលោកសម្រាប់ស្ត្រី និងយុត្តិធម៌ នៃសាលាច្បាប់ខរណែល ឆ្នាំ២០១១ កំណត់សម្គាល់លេខ ៧ ទំព័រទី៤០។

[53] ដូចដែលបានដកស្រង់សម្តី របស់មេធាវីផ្នែកសិទ្ធិមនុស្សម្នាក់នៅកម្ពុជានៅក្នុង ដូចខាងលើ ទំព័រទី៤១។

ទៅវិញ។ វ៉ាន់ សុភា ជឿថាជនល្មើសបានប្រគល់ប្រាក់សំណូកដល់មន្ត្រីនគរបាល ដើម្បីឲ្យពួកគេទាំងនោះដាក់សម្ពាធមកលើ វ៉ាន់ សុភា ឲ្យដកពាក្យបណ្តឹងវិញ បងប្រុសរបស់នាងបានជួយនាងដើម្បីបន្តនិងដោះស្រាយបញ្ហានៅក្រៅតុលាការ។ ជាលទ្ធផល នាងបានយល់ព្រមទទួលប្រាក់សំណងលើកដំបូង ចំនួន ១៥,០០០បាត (៤៧៥ដុល្លារ) និង ៥,០០០បាត (១៥៩ដុល្លារ) ក្នុងមួយឆ្នាំ បន្ទាប់ពីពេលនោះ រហូតដល់ឆ្នាំ២០១៤។ ការដោះស្រាយនេះត្រូវបានសម្រួលដោយមន្ត្រីនគរបាល ហើយ វ៉ាន់ សុភា និយាយថានាងត្រូវចំណាយឲ្យមន្ត្រីនគរបាលចំនួន ៥០០បាត (១៥ដុល្លារ) ក្នុងមួយឆ្នាំ ដើម្បីធានាថានាងនឹងបានទទួលប្រាក់សំណងទាំងនោះ។

# ៦. សវនាការ និងសាលក្រម

នៅពេលដែលការស៊ើបអង្កេតត្រូវបានធ្វើឡើង និងករណីព្រហ្មទណ្ឌត្រូវបានលើកឡើងប្រឆាំងនឹងជនដៃដល់ តុលាការ និងប្រព័ន្ធយុត្តិធម៌ជាអ្នកជានាការកាត់ទោសជនដៃដល់ដោយយុត្តិធម៌ និងអនុវត្តទណ្ឌកម្មឲ្យបានសមស្រប។ ករណីនេះមានសារៈសំខាន់ណាស់ ដែលមិនត្រឹមតែផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ការពារសាធារណជនទូទៅ និងពង្រឹងនីតិរដ្ឋប៉ុណ្ណោះទេ តែថែមទាំងអាចជាកត្តារារាំងបុគ្គលដទៃទៀតពីការប្រព្រឹត្តការវាយប្រហារស្រដៀងគ្នានេះផងដែរ។[54] ក្នុងឧទាហរណ៍មួយអំពីការកើនឡើងនូវនិទណ្ឌភាព ក្នុងការបង្ហាញប្រាប់ប្រជាពលរដ្ឋថាអាស៊ីដអាចជាអាវុធប្រើសម្រាប់បង្ករបួសស្នាមដ៏ជោគជ័យ មន្ត្រីជាន់ខ្ពស់ម្នាក់នៅក្នុងក្រសួងមហាផ្ទៃបានមានប្រសាសន៍ថា សេចក្តីសម្រេចរបស់សាលាដំបូងក្រុងភ្នំពេញ ដែលមិនចោទប្រកាន់ ជា រដ្ឋា នៅខែឧសភា ឆ្នាំ២០០៩ គឺជាករណីទីបីដែលតុលាការបានការពារលោកស្រីពីបទល្មើសអាស៊ីដ។[55] ជំពូកនេះត្រួតពិនិត្យមើលបញ្ហាចម្បងៗក្នុងសវនាការ និងដំណាក់កាលផ្តន្ទាទោសករណីបទល្មើសដោយអាស៊ីដ និងផលប៉ះពាល់ដែលមានមកលើភាពយុត្តិធម៌សម្រាប់ជនរងគ្រោះដោយអាស៊ីដ។

## ភាពអសកម្មនៃការវិនិច្ឆ័យទោស

ដោយមានឧបសគ្គដែលជនរងគ្រោះបានជួបប្រទះ ក្នុងការបញ្ជូនរឿងក្តីទៅដល់ដំណាក់កាលសវនាការ គឺហាក់ដូចជាគ្មានការភ្ញាក់ផ្អើលនោះទេ ដែលប្រសិនបើយោងតាម អ.ជ.ជ.ក.អ ៩០% នៃករណីពាក់ព័ន្ធនឹងអាស៊ីដមិនបានបញ្ជូនទៅតុលាការ។[56] ដូចបានពិភាក្សាក្នុងជំពូកមុន ក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងពីឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញាក្នុងការផ្តួចផ្តើមនីតិវិធីព្រហ្មទណ្ឌ។ ឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញានេះ រួមជាមួយនឹងទស្សនៈសង្គមអំពីការវាយប្រហារដោយអាស៊ីដ អាចប៉ះពាល់ដល់រឿងក្តីជាច្រើនដែលបានបញ្ជូនទៅតុលាការ។ ដូច្នេះ តួនាទីរបស់ព្រះរាជអាជ្ញាមានសារៈសំខាន់ណាស់ក្នុងការធានានូវនីតិវិធីដ៏ត្រឹមត្រូវ យុត្តិធម៌ និងសំណងសម្រាប់ជនរងគ្រោះ។ បញ្ហានេះត្រូវបានបញ្ជាក់បន្ថែមទៀត ក្នុងករណីរបស់បុរសម្នាក់នៅខេត្តព្រះសីហនុ ដែលបានទទួលដំណឹងថាសាលាឧទ្ធរណ៍មិនទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងសេចក្តីសម្រេចមិនចោទប្រកាន់ជនល្មើស ដែលវាយប្រហារដោយអាស៊ីដមកលើគាត់ឡើយ ព្រោះព្រះរាជអាជ្ញារងខេត្តព្រះសីហនុ ដែលជាកន្លែងកើត

[54] ម.ស.ម.ក និង អ.ជ.ជ.ក.អ កំណត់សម្គាល់បន្ថែមលេខ៦ ទំព័រ១១ ។

[55] សារព័ត៌មានឌឹ ខែមបូឌា ដេលី ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៩ "ក្រុមគ្រួសារជនរងគ្រោះដោយអាស៊ីដរៀបរាប់ពីការភ័យខ្លាច និងការគំរាមកំហែង" ។ គួរតែមានការកត់សម្គាល់ផងដែរថា សាលាឧទ្ធរណ៍ បន្ទាប់មកបានរកឃើញកំហុសរបស់លោកស្រី ដែលជាសេចក្តីសម្រេចដែលតុលាការកំពូលសម្រេចតម្កល់សាលក្រម។

[56] http://zeenews.india.com/news/world/cambodian-lawmakers-approve-law-on-acid-attacks_739966.html

ហេតុ មិនបានដាក់បណ្តឹងឧទ្ធរណ៍ឡើយ ។[57] ព្រះរាជអាជ្ញារងបានថ្លែងថា ខ្លួនមិនបានដាក់បណ្តឹងឧទ្ធរណ៍ព្រោះមិនមានភស្តុតាងគ្រប់គ្រាន់ ដែលជាមូលហេតុជនសង្ស័យមិនត្រូវបានចោទប្រកាន់នៅសាលាដំបូង ។[58] យោងតាមច្បាប់កម្ពុជា មានតែព្រះរាជអាជ្ញាប៉ុណ្ណោះដែលអាចដាក់បណ្តឹងឧទ្ធរណ៍អំពីអង្គហេតុ ឯប្រជាពលរដ្ឋ ដែលជាជនរងគ្រោះ អាចត្រឹមតែដាក់ពាក្យបណ្តឹងឧទ្ធរណ៍ដែលទាក់ទងនឹងប្រយោជន៍របស់ខ្លួនតែប៉ុណ្ណោះ ដូចជា កម្រិតនៃសំណង។ ដោយហេតុថាក្នុងទស្សនៈរបស់ព្រះរាជអាជ្ញាផ្ទាល់ លោកមិនមានមូលហេតុដើម្បីដាក់បណ្តឹងឧទ្ធរណ៍អំពីអង្គហេតុ ដូច្នេះធ្វើឲ្យជនរងគ្រោះមិនអាចដាក់ពាក្យបណ្តឹងសើរើបានឡើយ។

ក្នុងចំណោមករណីទាំងឡាយដែលបានបញ្ជូនទៅតុលាការ បែបបទក្នុងសវនាការគឺជាបញ្ហាដ៏គួរឲ្យបារម្ភ និងជំរុញនូវនិទណ្ឌភាព។ ឧទាហរណ៍ ដូចជាការដែលមិនចាំបាច់ត្រូវត្រួតពិនិត្យលើភស្តុ-តាងឲ្យបានច្បាស់លាស់។ ដូចបានពិភាក្សាកន្លងមកក្នុងរបាយការណ៍នេះ សវនាការជាញឹកញាប់ត្រូវបានធ្វើឡើងដោយកំបាំងមុខ ដូចនេះមិនមានការសួរចម្លើយជនដៃដល់ឲ្យបានត្រឹមត្រូវ ឬក្នុងករណីខ្លះមិនបានទទួលភស្តុតាងពីជនរងគ្រោះនោះទេ។ ជាងនេះទៅទៀត ទស្សនៈដែលថាអ្នកមានអំណាចនឹងមិនត្រូវបានកាត់ទោស ឬផ្តន្ទាទោសចំពោះទង្វើរបស់ពួកគេនៅតែជាបញ្ហាដ៏ជាក់ស្តែងមួយ។ តាត ម៉ារីណា មិនមានឱកាសប្រឈមមុខជាមួយនឹងអ្នកដែលវាយប្រហារលោកស្រីក្នុងតុលាការឡើយ។ តាមពិតទៅ ដូចយើងបានរៀបរាប់ក្នុងរបាយការណ៍នេះ លោកស្រីមិនបានដឹងថាតុលាការបានផ្តន្ទាទោសស្ត្រីដែលវាយប្រហារលោកស្រី និងអ្នកសមគំនិតនោះឡើយ រហូតទាល់តែដប់ឆ្នាំក្រោយមក។[59] តាមរយៈការផ្តន្ទាទោសកំបាំងមុខ ឃួន សុផល ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារចំនួនមួយឆ្នាំដោយព្យួរទោស។ បន្ទាប់ពីការផ្តន្ទាទោស ដីកាចាប់ខ្លួន ឃួន សុផល ត្រូវបានលុបចោល ចំណែក ឃួន សុផលនៅតែស្ថិតនៅក្រៅពន្ធនាគារ។[60]

ក្នុងខែឧសភា ឆ្នាំ២០០៨ មានការចេញដីកាចាប់ខ្លួន លោកស្រី ជា រដ្ឋា អគ្គស្នងការរងនៃទីបញ្ជាការប៉េអឹមលើផ្ទៃប្រទេស ដែលគេអះអាងថាលោកស្រីបានវាយប្រហារដោយអាស៊ីដលើលោកស្រី យ៉ា សុខនីម ដែលជាម្តាយមីងអតីតគូស្នេហ៍លោកស្រី ដោយមានការជួយពីអ្នកសមគំនិតជាច្រើននាក់។ ការវាយប្រហារនេះកើតឡើងក្នុងឆ្នាំ២០០៨ នៅពេលអង្គរក្សពីរនាក់ ក្នុងចំណោមអង្គរក្សជាច្រើននាក់ទៀតរបស់ ជា រដ្ឋា បានចាប់ លោកស្រី យ៉ា សុខនីម និងចាក់ទឹកអាស៊ីដលើមុខ និងដើម

[57] សារព័ត៌មានឌឹ ខែមបូឌា ដេលី ថ្ងៃទី១៤ ខែមិនា ឆ្នាំ២០១២ "សាលាឧទ្ធរណ៍បដិសេធមិនធ្វើសវនាការលើករណីអំពើហិង្សាដោយអាស៊ីដ" ។

[58] ដូចខាងលើ។

[59] សារព័ត៌មានឌឹ ខែមបូឌា ដេលី ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១១ "ការទើបតែបង្ហាញពីសាលក្រមនៃអំពើហិង្សាដោយអាស៊ីដគឺជាព័ត៌មានថ្មីសម្រាប់ តាត ម៉ារីណា" ។

[60] ឯកសារដែលផ្តល់ជូនដោយតុលាការ ។

ថ្ងៃ។ ទោះបីជាមានភស្តុតាងជាច្រើន រួមទាំងសំឡេងកិច្ចសន្ទនាតាមទូរស័ព្ទដែលគំរាមលោកស្រី យ៉ា សុខនីម ក៏ដោយ ប៉ុន្តែជា វង្ហា មិនត្រូវបានគេចាប់ខ្លួនឡើយ ហើយអាចគៀសខ្លួន និងបន្ទាប់មកមិនរង ការចោទប្រកាន់ពីតុលាការក្រុងភ្នំពេញ។ ទោះជាយ៉ាងណាក៏ដោយ សាលាឧទ្ធរណ៍លុបចោលសេចក្តី-សម្រេចដែលមិនបានចោទប្រកាន់ជនដៃដល់ ហើយកាត់ទោស ជា វង្ហា និងអ្នកសមគំនិតប្រាំនាក់ឲ្យជាប់ពន្ធនាគារពី១៥ ទៅ១៨ឆ្នាំ។ ចៅក្រម ស៊ី វុត្ថា និយាយថាមានភស្តុតាងច្រើនលើសលុបដើម្បីបញ្ជាក់ថាលោកស្រី ជា វង្ហា គឺជាមេក្លោងក្នុងការវាយប្រហារនេះ និងជនជាប់ចោទម្នាក់ទៀតចាក់ទឹកអាស៊ីដលើលោកស្រី យ៉ា សុខនីម ហើយជនជាប់ចោទទីបីគឺជាអ្នកបើកឡានដឹកពួកគេរត់គេច ៖ "*សេចក្តីថ្លែងការណ៍របស់សាក្សីពីរនាក់ មានលក្ខណៈដូចគ្នានឹងអ្វីដែលជនរងគ្រោះបានអះអាង និងបានបញ្ជាក់ថា មាស សៅ ជាអ្នកវាយប្រហារ... មាស សៅ និងសៀក ចាន់ឌី ជាអ្នកប្រព្រឹត្តបទឧក្រិដ្ឋ ហើយប្រសិនបើគ្មានបញ្ជាពី ជា វង្ហា ទេ ពួកគេនឹងគ្មានការជំរុញចិត្តឲ្យប្រព្រឹត្តអំពើនេះឡើយ*"។[61] នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១០ តុលាការកំពូលគាំទ្រតម្កល់ការផ្តន្ទាទោសនេះ។[62] ទោះបីជាមានការកាត់ទោសបែបនេះក៏ដោយ ក្រុមជនដៃដល់នៅកំពុងលាក់ខ្លួននៅឡើយ ដោយ ជា វង្ហា បានបាត់ខ្លួនចាប់តាំងពីការវាយប្រហារ ហើយលោកស្រីប្រហែលជាមិនត្រូវទទួលទោសអ្វីឡើយ។[63]

# ការដាក់ទណ្ឌកម្ម និងសំណង

## ការកាត់ទោស

បន្ថែមលើការកាត់ទោស ឃួន សុផល និងជា វង្ហា ដោយកំបាំងមុខ មានករណីមួយចំនួនទៀតត្រូវបានរាយការណ៍ថាជនរងគ្រោះទទួលបានយុត្តិធម៌។ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១១ តុលាការក្រុងភ្នំពេញកាត់ទោសមនុស្សបីនាក់ ដោយពួកគេពាក់ព័ន្ធនឹងការវាយប្រហារស្ត្រីពីរនាក់ដោយ អាស៊ីដនៅក្នុងខែមករា។ ហាវ ឡា ដែលជាអ្នកប្រព្រឹត្តបទឧក្រិដ្ឋ ត្រូវកាត់ទោសឲ្យជាប់ពន្ធនា-គារបីឆ្នាំ។ ស្វាមីរបស់ ហាវ ឡា ឈ្មោះណេ ផានិត និងប្អូនប្រុសថ្លៃឈ្មោះណេ ផាណែត ត្រូវបានរកឃើញថាមានទោសពីបទបង្កអំពើហិង្សាដោយចេតនា និងត្រូវកាត់ទោសឲ្យជាប់ពន្ធនាគារ បួនឆ្នាំ និងបីឆ្នាំ ដោយឡែកពីគ្នា។ សារៈសំខាន់នៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង គឺនៅត្រង់សាលក្រមដែលមានការខុសឆ្គង និងការកាត់ទោសឲ្យជនដៃដល់ និងអ្នកញុះញង់ឲ្យជាប់ពន្ធនាគាររយៈពេលខ្លី។ នៅពេលករណីនេះកើតឡើង ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងនៅមិនទាន់ចូលជាធរមានដូច្នេះទើបបានការអនុវត្តន៍ទោសមានកម្រិតស្រាល គឺបទចោទប្រកាន់អំពើហិង្សាដោយចេតនា។[64] ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង

---

61 សារព័ត៌មាន ឌឹ ខែមបូឌា ដេលី កំណត់សម្គាល់បន្ថែមលេខ២៥ ។

62 វីអូ អេ ខ្មែរ ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១០ "តុលាការកំពូលតម្កល់សាលក្រមក្នុងករណីអំពើហិង្សាដោយអាស៊ីដ" អាចអានបាន ៖ http://www.voanews.com/khmer-english/news/Supreme-Court-Upholds-Acid-Attack-Verdict-104427959.html (ចូលអានលើកចុងក្រោយ ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២)។

63 ដូចខាងលើ

64 សារព័ត៌មាន ឌឹ ខែមបូឌា ដេលី ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ "តុលាការរាជធានីភ្នំពេញ ផ្តន្ទាទោស បុគ្គល៣នាក់ ក្នុងអំពើវាយប្រហារដោយអាស៊ីដ" ។

ទទួលស្គាល់ថា ផលប៉ះពាល់នៃការវាយប្រហារដោយអាស៊ីដមានលើសពី "ការវាយប្រហារ" តែ "វាយប្រហារ" ដែលត្រូវធានាបន្ថែមនូវយុត្តិធម៌សម្រាប់អ្នកដែលនៅរស់ ដោយអនុវត្តវិធានការកាត់ទោសដែលសមាមាត្រនឹងរបួសស្នាមដែលបានបង្កឡើង។

ទោះជាយ៉ាងណាក៏ដោយ ពិតជាមានសារៈសំខាន់ដូចគ្នាដែលថា ភាពស្មុគស្មាញដែលនៅជុំវិញករណីវាយប្រហារដោយអាស៊ីដ មិនអាចគ្របលើសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានយុត្តិធម៌ និងសំណងនោះឡើយ។ នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១ តុលាការខេត្តកំពង់ចាមកាត់ទោសស្ត្រីអាយុ២៥ឆ្នាំម្នាក់ ឲ្យស្ថិតក្រោមការឃ្លាំមើលរយៈពេល៣ឆ្នាំ ជំនួសឲ្យការជាប់ពន្ធនាគាររយៈពេលពីរឆ្នាំដោយស្រោចទឹកអាស៊ីដលើម្ដាយ និងកូនពីរនាក់។ ការកាត់ទោសឲ្យស្ថិតនៅក្រោមការឃ្លាំមើលត្រូវបានធ្វើឡើងដោយផ្អែកលើមូលហេតុដែលថា ជនដៃដល់បានរងរបួសក្នុងអំឡុងពេលវាយប្រហារ ហើយទាមទារឲ្យមានការព្យាបាល។[65] ទោះបីជាជនដៃដល់មិនគួរត្រូវបានបដិសេធចំពោះការយកចិត្តទុកដាក់ផ្នែកវេជ្ជសាស្ត្រ ពាក់ព័ន្ធនឹងការវាយប្រហារក៏ដោយ ប៉ុន្តែយុត្តិធម៌ និងសំណងសម្រាប់ជនរងគ្រោះក៏មានសារសំខាន់ផងដែរ។

## ការអនុវត្តន៍ទណ្ឌកម្ម

នៅពេលដែលសាលក្រមត្រូវបានប្រកាស បញ្ហាសំខាន់ក្នុងវដ្តនៃនិទណ្ឌភាពគឺកង្វះខាតនូវការអនុវត្តន៍ទណ្ឌកម្ម។ ជាគុពិតដែលរឿងក្ដីមួយចំនួនក្នុងរឿងក្ដីទាំងនេះ ត្រូវបានជំនុំជំរះដោយកំបាំងមុខជនជាប់ចោទ ធ្វើឲ្យជនដៃដល់គិតថាខ្លួនពិតជាមិនទំនងនឹងត្រូវគេចាប់ដាក់ពន្ធនាគារឡើយ។ ជាពិសេសក្នុងករណីរបស់ ជា រដ្ឋា និងអ្នកសមគំនិតជាមួយលោកស្រី ស្ទើរតែមួយខែបន្ទាប់ពីសាលាឧទ្ធរណ៍បានកាត់ទោសលោកស្រីនៅឆ្នាំ២០០៩ ស្នងការនគរបាលរាជធានីភ្នំពេញលោក ទូច ណារ៉ុថ បាននិយាយថាកម្លាំងរបស់គាត់មិនទាន់បានទទួលដីកាចាប់ខ្លួនចុងក្រោយនៅឡើយ។[66] យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាមានឆន្ទានុសិទ្ធិ នៅពេលមានការចេញដីកាចាប់ខ្លួនបន្ទាប់ពីកាត់ទោសអ្នកដែលត្រូវគេចោទប្រកាន់ ដែលបុគ្គលនោះមិនមានវត្តមានក្នុងសវនាការ។[67] ហេតុដូច្នេះ ជាថ្មីម្ដងទៀត ឆន្ទានុសិទ្ធិក្នុងប្រព័ន្ធយុត្តិធម៌មានតួនាទីក្នុងការធ្វើឲ្យមាននិទណ្ឌភាព។ ផលប៉ះពាល់នៃឆន្ទានុសិទ្ធិនេះក្នុងប្រព័ន្ធតុលាការ គឺការងាយរងឥទ្ធិពលពីការសូកប៉ាន់ និងត្រូវបានចាត់ទុកថាខ្វះឯករាជ្យភាពគឺសំខាន់ណាស់។ កង្វះខាតនូវដីកាចាប់ខ្លួនដែលត្រូវប្រើប្រាស់ទាំងក្នុងដំណាក់កាលស៊ើបអង្កេត និងបន្ទាប់ពីការកាត់ទោសធ្វើឲ្យវដ្តនៃនិទណ្ឌភាពបន្តកើតមានឡើង និងឆ្លុះបញ្ចាំងពី

[65] សារព័ត៌មាន ឌឹ ខែមបូឌា ដេលី ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១ "ស្ត្រីម្នាក់ទទួលទោសបណ្ដោះអាសន្នរយៈពេល ៣ឆ្នាំ ក្នុងករណីវាយប្រហារដោយអាស៊ីដ" ។
[66] សារព័ត៌មាន ឌឹ ខែមបូឌា ដេលី ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ "ជនល្មើសក្នុងអំពើហិង្សាដោយអាស៊ីដ រត់គេចខ្លួនទៅប្រទេសថៃ តាមសម្ដីរបស់មន្ត្រី" ។
[67] មាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រព័ន្ធតុលាការក្នុងប្រទេសកម្ពុជាដែលជួយតែអ្នកមាន និងអ្នកមានអំណាចក្នុងផ្ទុត់គំនិតរបស់ជនរងគ្រោះ។

ការដែលជនរងគ្រោះទទួលបានសំណងដោយពិតប្រាកដ នៅតែចោទជាបញ្ហាសំខាន់ជុំវិញបញ្ហានិទណ្ឌភាព និងការស្វែងរកសំណង។ ការផ្តល់សំណងមានសារសំខាន់ខ្លាំងណាស់ ដោយហេតុថាបន្ទាប់ពីរងការវាយប្រហារ ជនរងគ្រោះមិនមានលទ្ធភាពផ្គត់ផ្គង់គ្រួសារ ជាពិសេសនៅពេលដែលពួកគេត្រូវបង់ថ្លៃថ្នាំពេទ្យ និងថ្លៃសេវាកម្មច្បាប់ ដែលធ្វើឲ្យពួកគេធ្លាក់ខ្លួនក្រ។ ខណៈពេលដែល ក្នុងការអនុវត្តន៍សេចក្តីសម្រេច តុលាការអាចបង្គាប់ឲ្យជនដៃដល់បង់ប្រាក់សំណង ប៉ុន្តែជនរងគ្រោះត្រូវចំណាយថវិកាផ្ទាល់ខ្លួនដើម្បីដំណើរការនីតិវិធីរដ្ឋប្បវេណី។[68]

---

ក្នុងឆ្នាំ១៩៩៤ ដោគ ជតា ត្រូវបានសហការីភេទស្រីម្នាក់នៅភោជនីយដ្ឋានដែលខ្លួនបម្រើការងារវាយប្រហារដោយសារស្ត្រីនោះខឹងគាត់ដោយគាត់ប្រឡងជាប់ការប្រកួតចម្រៀងខារ៉ាអូខេ។ ការវាយប្រហារនេះបណ្តាលឲ្យគាត់ពិការភ្នែកទាំងគូ ហើយត្រចៀកខាងស្តាំរបស់គាត់ស្តាប់លែងឮ។ គាត់បានដាក់ពាក្យបណ្តឹងបន្ទាប់ពីមានការវាយប្រហារ ហើយឧក្រិដ្ឋជនត្រូវបានចាប់ខ្លួន។ ដោគ ជតា មានវត្តមានក្នុងសវនាការជំណាក់កាលដំបូងក្នុងតុលាការរាជធានីភ្នំពេញ និងបន្ទាប់មកទៀតដោយការប្តឹងទៅកាន់សាលាឧទ្ធរណ៍ មុនពេលបានស្តាប់សេចក្តីសម្រេចរបស់ស្ត្រីដែលបានស្រោចទឹកអាស៊ីដលើគាត់ ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារបីឆ្នាំ និងផ្តល់ប្រាក់សំណងជាមាសបួនដម្លឹង។

ប៉ុន្តែ រហូតដល់សព្វថ្ងៃនេះ ដោគ ជតា មិនបានទទួលសំណងអ្វីឡើយ។ គាត់ក៏មិនបានដឹងថាតើជនដៃដល់ត្រូវបានចាប់ដាក់ពន្ធនាគារហើយឬនៅឡើយ។ ភរិយារបស់គាត់បានចាកចេញពីគាត់បន្ទាប់ពីការវាយប្រហារបានកើតឡើង ដូច្នេះ គាត់ត្រូវរស់នៅជាមួយម្តាយចាស់ជរា និងត្រូវបានបង្ខំចិត្តឲ្យសុំទានដើម្បីផ្គត់ផ្គង់ការរស់នៅ ។

---

ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងមានសក្តានុពលក្នុងការដើរតួនាទីយ៉ាងសំខាន់ នៅពេលមានការផ្តល់ជាសំណងតាមរយៈការគាំពារផ្នែកច្បាប់ ការព្យាបាល ក៏ដូចជាការការពារ ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មជួយជនរងគ្រោះឲ្យអាចរស់នៅក្នុងសង្គមវិញបាន។[69]ចំពោះការគាំពារផ្នែកច្បាប់ជនរងគ្រោះ ត្រូវមានលទ្ធភាពប្រើប្រាស់ការគាំពារដែលត្រូវផ្តល់ជូនតាមរយៈច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ដើម្បីបន្តសំនុំរឿងរដ្ឋប្បវេណី ដើម្បីទាមទារសំណងដែលជនដៃដល់ត្រូវសងទៅឲ្យពួកគេ។ ចំពោះការព្យាបាល ការដែលច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងខកខានមិនបានកំណត់ការគាំពារឲ្យបានដាក់

[68] ក្រសួងយុត្តិធម៌ និងកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា "មាគ៌ាទៅរកយុត្តិធម៌ ៖ ការទទួលបានយុត្តិធម៌ ដោយផ្តោត លើជនក្រីក្រ ស្ត្រី និងជនជាតិដើម" ទំព័រ៨៥ ។

[69] សូមអានមាត្រា១០ - ១២ នៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង។

លាក់ ជាពិសេសចំពោះការវះកាត់កែសម្ផស្សដែលត្រូវចំណាយពេលយូរហេូតដល់ជាច្រើនឆ្នាំ បន្ទាប់ពីការវាយប្រហារ បានបង្កឲ្យមានផលលំបាកជាក់លាក់ជាច្រើន។ ទោះបីជាមានសំណូមពរក្នុងអំឡុងការ វែកញែកក្នុងរដ្ឋសភាលើច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង អ្នកនាំពាក្យក្រសួងមហាផ្ទៃម្នាក់ បាននិយាយថា ការព្យាបាលមិនអាចផ្តល់ជូនពេញមួយជីវិតនោះទេ សំណួរពាក់ព័ន្ធនឹងការផ្តល់សំណង នៅតែមានសារៈសំខាន់ ព្រោះជាមធ្យោបាយធានាយុត្តិធម៌ និងសំណងដល់ជនរងគ្រោះ។

# ៧. សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

ការអនុម័តនីតិកម្មជាក់លាក់មួយដើម្បីដោះស្រាយអំពើហិង្សាដោយអាស៊ីដ និងផលវិបាកដែលពាក់ព័ន្ធទាំងឡាយ ត្រូវបានកោតសរសើរដោយមនុស្សជាច្រើន ថាជាជំហានមួយដ៏សំខាន់ក្នុងការដោះស្រាយចំពោះបញ្ហាការប្រព្រឹត្តអំពើហិង្សាដ៏ឃោរឃៅ និងយង់ឃ្នងទាំងនេះ និងជាជំហានផ្នែកច្បាប់ ដ៏សំខាន់ក្នុងការបំបាត់វប្បធម៌និទណ្ឌភាពដែលនៅជុំវិញអំពើហិង្សាដោយអាស៊ីដ។ ជាលាយ-លក្ខណ៍អក្សរ ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងបានរាប់បញ្ចូលបញ្ញត្តិសំខាន់ៗ ដែលអាចជះឥទ្ធិពលសំខាន់ និងវិជ្ជមានក្នុងការបញ្ចប់វដ្តនៃនិទណ្ឌភាព ដូចជា ការផ្ដន្ទាទោសឲ្យបានតឹងរឹង។ មិនតែប៉ុណ្ណោះ ដូចដែលបានលើកយកមកពិភាក្សាក្នុងរបាយការណ៍ បញ្ញត្តិក្នុងច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងដែលពាក់ព័ន្ធនឹងរដ្ឋក្នុងការផ្ដល់ការព្យាបាល និងការគាំទ្រផ្នែកច្បាប់ អាចកាត់បន្ថយឧបសគ្គផ្នែកហិរញ្ញវត្ថុ ដែលពីមុនបានបង្ខំឲ្យជនរងគ្រោះសុខចិត្តដោះស្រាយនៅក្រៅតុលាការ។

ចុងក្រោយ ភាពជោគជ័យនៃច្បាប់គ្រប់គ្រងអាស៊ីដខ្លាំងក្នុងការបញ្ចប់វដ្តនៃនិទណ្ឌភាព និងបញ្ចប់អំពើហិង្សាដោយអាស៊ីដនៅកម្ពុជា គឺត្រូវផ្អែកទៅលើការអនុវត្តច្បាប់យ៉ាងមានប្រសិទ្ធភាព និងធានាថាប្រព័ន្ធយុត្តិធម៌គាំទ្រឲ្យមានការស៊ើបអង្កេត ការផ្ដន្ទាទោស និងការដោះស្រាយឲ្យបានត្រឹមត្រូវចំពោះការប្រព្រឹត្តអំពើហិង្សាដោយអាស៊ីដ។ ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង នឹងគ្មានប្រសិទ្ធភាពក្នុងការលុបបំបាត់អំពើហិង្សាដោយអាស៊ីដ និងនិទណ្ឌភាពដែលអមជាមួយ ប្រសិនបើជនរងគ្រោះនៅតែងាយរងគ្រោះ ហើយនៅមានភាពភ័យខ្លាចចំពោះការសងសឹក និងការផ្ចាញ់តប ដែលជាការរារាំងពួកគេមិនឲ្យដាក់ពាក្យប្ដឹង។ ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង នឹងគ្មានប្រសិទ្ធភាពក្នុងការលុបបំបាត់អំពើហិង្សាដោយអាស៊ីដ និងនិទណ្ឌភាព ប្រសិនបើមន្ត្រីនគរបាល និងអាជ្ញាធរមិនបានរាប់បញ្ចូលការស៊ើបអង្កេតឲ្យបានសមស្រប និងទាន់ពេលវេលា និងធានានូវសុវត្ថិភាព និងសន្តិសុខសម្រាប់សាក្សី។ ច្បាប់គ្រប់-គ្រងអាស៊ីដខ្លាំង នឹងគ្មានប្រសិទ្ធភាពក្នុងការលុបបំបាត់អំពើហិង្សាដោយអាស៊ីដ និងនិទណ្ឌភាព ប្រសិនបើការស៊ើបអង្កេត និងឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញាត្រូវបានបំផ្លាញ ដោយបុរេនិច្ឆ័យជុំវិញអំពើហិង្សាដោយអាស៊ីដ។ ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង នឹងគ្មានប្រសិទ្ធភាពក្នុងការលុបបំបាត់អំពើហិង្សាដោយអាស៊ីដ និងនិទណ្ឌភាព ប្រសិនបើថ្លៃចំណាយក្នុងការព្យាបាល និងការបន្តនីតិវិធីផ្នែកច្បាប់ បានរារាំងជនរងគ្រោះមិនឲ្យទទួលផលប្រយោជន៍ពីអនុភាពច្បាប់ទាំងមូល ដែលបង្ខំឲ្យពួកគេព្រមទទួលការដោះស្រាយដែលមានប្រាក់សំណងមិនគ្រប់គ្រាន់ និងមិនគួរឲ្យជឿទុកចិត្តបាន។ ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង នឹងគ្មានប្រសិទ្ធភាពក្នុងការលុបបំបាត់អំពើហិង្សាដោយអាស៊ីដ និងនិទណ្ឌភាព ប្រសិនបើប្រព័ន្ធតុលាការខកខានក្នុងការធានាថា លក្ខខណ្ឌដ៏សមស្របមួយត្រូវបានបង្កើតឡើងក្នុងសេចក្ដី-

សម្រេច ដើម្បីធានាថាជនដែលត្រូវបានវិនិច្ឆ័យទោស ត្រូវតែទទួលទោស ហើយផ្តល់ឲ្យជនរងគ្រោះនូវសំណងដ៏សមស្របមួយ។

កត្តាទាំងអស់ ក្នុងប្រព័ន្ធយុត្តិធម៌ ដូចជា មន្ត្រីនគរបាល ព្រះរាជអាជ្ញា មន្ត្រីតុលាការ មានតួនាទីដ៏សំខាន់ដើម្បីបញ្ចប់វដ្តនៃនិទណ្ឌភាព ដែលជាប់ពាក់ព័ន្ធនឹងអំពើហិង្សាដោយអាស៊ីដ និងធានាឲ្យមានការផ្តន្ទាទោសចំពោះជនល្មើសយ៉ាងមានប្រសិទ្ធភាព។ ចុងបញ្ចប់ ម.ស.ម.ក សូមផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោម ដល់រដ្ឋាភិបាល ប្រព័ន្ធយុត្តិធម៌ ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ៖

**ការដាក់ពាក្យបណ្តឹង**

- រដ្ឋាភិបាលគួរតែអនុម័តអនុក្រឹត្យ បញ្ជាក់បន្ថែមលើបញ្ញត្តិក្នុងច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ដើម្បីចែងពីការផ្តល់ការព្យាបាល និងការគាំពារផ្នែកច្បាប់សម្រាប់ជនរងគ្រោះដោយអាស៊ីដ ដើម្បីឲ្យពួកគេបានដឹងពីដំណោះស្រាយដែលរដ្ឋនឹងត្រូវផ្តល់ជូនពួកគេ និងធ្វើឲ្យពួកគេមិនចាំបាច់ត្រូវវារែក ដោយសារតែឧបសគ្គផ្នែកហិរញ្ញវត្ថុ ហើយយល់ព្រមដោះស្រាយបញ្ហាក្រៅតុលាការ។
- បញ្ញត្តិនៅក្នុងអនុក្រឹត្យដែលនិយាយខាងលើ គួរតែចែងឲ្យបានជាក់លាក់ថា ជំនួយផ្នែកច្បាប់ និងកោសល្យវិច្ច័យដែលជាភស្តុតាងនឹងត្រូវបានផ្តល់ទៅជនរងគ្រោះ មុនពេល និងក្នុងអំឡុងពេលនៃនីតិវិធីតុលាការ ហើយការគាំពារបែបនេះនឹងត្រូវផ្តល់ជូនដោយឥតគិតថ្លៃ និងត្រូវផ្តល់ជូនក្នុងពេលវេលាដ៏សមរម្យមួយ។ ត្រូវតែមានការធានាថាជំនួយផ្នែកច្បាប់នឹងត្រូវបានផ្តល់ជូនទាំងក្នុងករណីព្រហ្មទណ្ឌ និងរដ្ឋប្បវេណី។
- ដើម្បីជួយកាត់បន្ថយភាពភ័យខ្លាចដែលជនរងគ្រោះ និងសាក្សីមាន ចំពោះបញ្ហាសុវត្ថិភាព និងសន្តិសុខរបស់ពួកគេ ពេលដែលគេដាក់ពាក្យប្តឹងមកមន្ត្រីនគរបាល ឬក៏ផ្តល់ភស្តុតាងពាក់ព័ន្ធនឹងអំពើហិង្សាដោយអាស៊ីដ រដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌គួរតែធានាថានឹងមានការការពារជនរងគ្រោះ និងសាក្សី នៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការយុត្តិធម៌។
- ថ្លៃចំណាយលើកោសល្យវិច្ច័យគួរតែត្រូវបានទទួលការឧបត្ថម្ភពីរដ្ឋាភិបាល ក្រោមច្បាប់គ្រប់-គ្រងអាស៊ីដខ្លាំង ក្នុងបញ្ញត្តិការគាំពារផ្នែកច្បាប់។ មិនតែប៉ុណ្ណោះ មន្ត្រីនគរបាល និងតុលាការគួរតែទទួលស្គាល់កោសល្យវិច្ច័យទាំងនោះ ដោយមិនគិតពីវេជ្ជបណ្ឌិត ឬស្ថាប័នដែលផ្តល់កោសល្យវិច្ច័យនោះទេ ដោយចែងថាវេជ្ជបណ្ឌិត ឬស្ថាប័នដែលមានអាជ្ញាបណ្ណត្រឹមត្រូវ និងបានចុះបញ្ជីដើម្បីធ្វើការព្យាបាលជូនប្រជាពលរដ្ឋ។

## ការស៊ើបអង្កេត

- រដ្ឋាភិបាលគួរតែពិចារណាធ្វើវិសោធនកម្មច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ឲ្យប្រហាក់ប្រហែលទៅនឹងអ្វីដែលបានឃើញ ក្នុងច្បាប់ប្រទេសបង់ក្លាដែស ជុំវិញការស៊ើបអង្កេតមកលើករណីបទល្មើសដោយអាស៊ីដឲ្យបានទាន់ពេលវេលា និងផ្តន្ទាទោសឲ្យបានស័ក្តិសមមកលើមន្ត្រីនគរ-បាល ព្រះរាជអាជ្ញា និងសមាជិកក្នុងប្រព័ន្ធយុត្តិធម៌ដែលបានធ្វេសប្រហែសក្នុងការស៊ើប-អង្កេត ឬរាំងស្ទះដំណើរការយុត្តិធម៌ ដូចជាព្យាយាមសម្រួលឲ្យមានការដោះស្រាយក្រៅតុលា-ការ ព្រោះតែមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុសម្រាប់ខ្លួនគេផ្ទាល់។
- ក្រសួងមហាផ្ទៃ គួរតែធានាថាមន្ត្រីប៉ូលីសទាំងអស់ ទទួលការបណ្តុះបណ្តាលបានត្រឹមត្រូវដើម្បីស៊ើបអង្កេតករណីអំពើហិង្សាដោយអាស៊ីដឲ្យមានប្រសិទ្ធភាព និងសមរម្យ។
- ក្រសួងមហាផ្ទៃ គួរតែផ្តល់នូវការបណ្តុះបណ្តាលសម្រាប់មន្ត្រីនគរបាលពីរឿងការអនុវត្តន៍ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង ក៏ដូចជា បណ្តុះបណ្តាលកម្មវិធីការពារជនរងគ្រោះ និងសាក្សី និងភាពដែលងាយប៉ះពាល់ដល់យេនឌ័រ។

## ការផ្តន្ទាទោស

- ក្រសួងយុត្តិធម៌ រួមជាមួយក្រសួងមហាផ្ទៃ គួរផ្តល់ការបណ្តុះបណ្តាលចំពោះព្រះរាជអាជ្ញា និងមន្ត្រីតុលាការដទៃទៀត ស្តីពីការអនុវត្តន៍ច្បាប់គ្រប់គ្រងអាស៊ីដខ្លាំង។
- ក្រសួងយុត្តិធម៌ រួមជាមួយក្រសួងមហាផ្ទៃ គួរតែបោះពុម្ពផ្សាយសេចក្តីណែនាំពី ច្បាប់គ្រប់-គ្រងអាស៊ីដខ្លាំង ទៅដល់ចៅក្រមដើម្បីធានាថាពួកគេបានយល់ពីបញ្ញត្តិការដាក់ទោស និងភាពសមាមាត្រជុំវិញការផ្តន្ទាទោស និងរបួសដែលកើតមាន។

# ៨. គន្ថនិទ្ទេស

## ច្បាប់ជាតិ កតិកាសញ្ញា និងសេចក្តីប្រកាស

ច្បាប់គ្រប់គ្រងបទល្មើសអាស៊ីដរបស់ប្រទេសបង់ក្លាដែស (អនុម័តថ្ងៃទី១៧ ខែមិនា ឆ្នាំ២០០២)

សភាអឺរ៉ុប ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០ "សេចក្តីប្រកាសរបស់សភាអឺរ៉ុប នៅថ្ងៃទី២១ ខែតុលា ឆ្នាំ ២០១០ នៅកម្ពុជា ជាពិសេសក្នុងករណី លោក សម រង្ស៊ី" កំណត់ហេតុផ្លូវការរបស់សហភាពអឺរ៉ុប C/70 E/10 ។

ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម របស់អង្គការសហប្រជាជាតិ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៥ "បណ្តុំគោលការណ៍ដើម្បីការការពារ តាមរយៈសកម្មភាពបំបាត់និទណ្ឌភាព និងលើកដម្កើងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ" E/CN.4/2005/102/Add 1។

គោលការណ៍មូលដ្ឋាន របស់អង្គការសហប្រជាជាតិ ស្តីពីយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារបទ-ល្មើស និងការប្រើអំណាចខុសច្បាប់ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ សេចក្តីប្រកាសរបស់មហា-សន្និបាត លេខ៤០/៣៤។

## ច្បាប់កម្ពុជា

ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង (២០០១)
ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (២០០៧)

## របាយការណ៍ និងការបោះពុម្ពផ្សាយ

មជ្ឈមណ្ឌល អាវ៉ែន ពិភពលោកសម្រាប់ស្ត្រី និងយុត្តិធម៌ គណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្សអន្តរជាតិនៃគណៈមេធាវីទីក្រុងញូវយ៉ក គ្រឹះស្ថានសិទ្ធិមនុស្សនៃសាលាច្បាប់អន្តរជាតិខរណែល និងមូលនិធិគុណធម៌ ឆ្នាំ២០១១ របាយការណ៍ "*លុបបំបាត់អំពើហិង្សាដោយអាស៊ីដនៅប្រទេស បង់ក្លាដែស ឥណ្ឌា និងកម្ពុជា*"។

អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីដ របាយការណ៍ប្រចាំឆ្នាំ ២០០៩ អាចរកអានបាន៖ www.cambodianacidsurvivorscharity.org/annual%20report2009.pdf ។

អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីដ និងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ខែឧសភា ឆ្នាំ ២០១០ របាយការណ៍ "យើងនាំគ្នាបញ្ឈប់អំពើហិង្សាដោយអាស៊ីដ នៅកម្ពុជា" ។

ក្រសួងយុត្តិធម៌ និងកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា "មាគ៌ាទៅរកយុត្តិធម៌ ៖ ការទទួលបានយុត្តិធម៌ ដោយផ្តោតលើជនក្រីក្រ ស្ត្រី និងជនជាតិដើម" ។

អ្នកតំណាងពិសេសទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ខែកញ្ញា ឆ្នាំ២០១០ "របាយការណ៍របស់អ្នកតំណាងពិសេសទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា A/HRC/15/46 ។

## អត្ថបទសារព័ត៌មាន និងសេចក្តីប្រកាសព័ត៌មាន

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១១ "វិចារណកថាព័ត៌មាន ៖ ការខកខានមិនព្រមចេញដីកាចាប់ខ្លួន បងប្អូនជីដូនមួយរបស់លោកនាយករដ្ឋមន្ត្រី បង្ហាញពីវប្បធម៌និទណ្ឌភាពនៅកម្ពុជា" អាចអានបាន ៖ http://www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=202&id=5 (ចូលអានលើកចុងក្រោយ ថ្ងៃទី២០ ខែមេសា ឆ្នាំ ២០១២)។

សារព័ត៌មាន ឌឹ ខែមបូឌា ដេលី ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៩ "ក្រុមគ្រួសារជនរងគ្រោះដោយអាស៊ីដរៀបរាប់ពីការភ័យខ្លាច និងការគំរាមកំហែង"

- ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ "មេធាវីស្វែងរកជំនួយពីលោក សុខ អាន ក្នុងករណីការវាយប្រហារដោយអាស៊ីដ"
- ថ្ងៃទី២៨ - ២៩ ខែវិច្ឆិកា ឆ្នាំ២០០៩ "តុលាការលុបចោលសេចក្តីសម្រេចដែលមិនបានចោទ-ប្រកាន់ជនដៃដល់ក្នុងការវាយប្រហារដោយអាស៊ីដ"
- ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ "ជនល្មើសក្នុងអំពើហិង្សាដោយអាស៊ីដ រត់គេចខ្លួនទៅប្រទេសថៃតាមសម្តីរបស់មន្ត្រី"
- ថ្ងៃទី២០ ខែមករា ឆ្នាំ២០១១ "មនុស្ស៣នាក់ ត្រូវបានចាប់ខ្លួនក្នុងករណីអំពើវាយប្រហារដោយអាស៊ីដក្នុងឆ្នាំ២០១១"
- ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១ "ស្ត្រីម្នាក់ទទួលទោសបណ្តោះអាសន្នរយៈពេល ៣ឆ្នាំ ក្នុងករណីវាយប្រហារដោយអាស៊ីដ"
- ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ "តុលាការរាជធានីភ្នំពេញ ផ្តន្ទាទោស មនុស្ស៣នាក់ ក្នុងអំពើវាយប្រហារដោយអាស៊ីដ"

- ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១១ "របាយការណ៍បានបង្ហាញពីការវិនិច្ឆ័យទោស នៃករណីវាយប្រហារដោយអាស៊ីដក្នុងឆ្នាំ១៩៩៩"
- ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១១ "ការទើបតែបង្ហាញពីសាលក្រមនៃអំពើហិង្សាដោយអាស៊ីដគឺជាព័ត៌មានថ្មីសម្រាប់ តាត ម៉ារីណា"
- ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ "ដីកាចាប់ខ្លួនបងប្អូនជីដូនមួយលោក ហ៊ុន សែន ហាក់ដូចជាមិនត្រូវបានចេញដោយឆាប់រហ័សនោះទេ"
- ថ្ងៃទី០៤ ខែមករា ឆ្នាំ២០១២ "ចំនួនករណីវាយប្រហារដោយអាស៊ីដ ធ្លាក់ចុះជិតពាក់កណ្តាលក្នុងអំឡុងឆ្នាំ២០១១"
- ថ្ងៃទី១០-១១ ខែមិនា ឆ្នាំ២០១២ "មនុស្សពីរនាក់រងការវាយប្រហារដោយអាស៊ីដ ភរិយាគឺជាជនសង្ស័យសំខាន់ម្នាក់"
- ថ្ងៃទី២៩ ខែមិនា ឆ្នាំ២០១២ "មន្ត្រីនគរបាលស្នើសុំដីកាចាប់ខ្លួនជនសង្ស័យនៃអំពើវាយ-ប្រហារដោយអាស៊ីដ"
- ថ្ងៃទី១៤ ខែមិនា ឆ្នាំ២០១២ "សាលាឧទ្ធរណ៍បដិសេធមិនធ្វើសវនាការលើករណីអំពើហិង្សាដោយអាស៊ីដ"
- ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ "ករណីវាយប្រហារដោយអាស៊ីដលើកទីបី ក្នុងឆ្នាំនេះបានទុកឲ្យស្ត្រីម្នាក់រងរបួសធ្ងន់ធ្ងរ"

*សារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្តិ៍* ថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ "តុលាការចោទប្រកាន់មនុស្ស ៣នាក់ឲ្យឲ្យជាប់ទោសក្នុងករណីអំពើហិង្សាដោយអាស៊ីដ"

- ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ "មនុស្ស ៣នាក់ត្រូវបានចោទប្រកាន់ក្នុងករណីអំពើហិង្សាដោយអាស៊ីដ"
- ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១ "ស្ត្រីត្រូវបានចាប់ខ្លួនក្នុងរយៈពេល ៣ឆ្នាំ ក្រោយការវាយប្រហារ"
- ថ្ងៃទី០២ ខែមិនា ឆ្នាំ២០១២ "ជនល្មើសនៃអំពើហិង្សាដោយអាស៊ីដនៅតែមានសេរីភាព បើយោងតាមមន្ត្រីនគរបាល"
- ថ្ងៃទី១២ ខែមិនា ឆ្នាំ២០១២ "ការវាយប្រហារដោយអាស៊ីដបានផ្តាច់ជីវិតបុរសម្នាក់"
- ថ្ងៃទី២១ ខែមិនា ឆ្នាំ២០១២ "មន្ត្រីនគរបាលអាចកំណត់ជនសង្ស័យក្នុងករណីវាយប្រហារដោយអាស៊ីដ"
- ថ្ងៃទី២៨ ខែមិនា ឆ្នាំ២០១២ "ជនរងគ្រោះដោយអាស៊ីដស្វែងរកការជួយសង្គ្រោះ"

- ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ "ករណីវាយប្រហារលើកទីបី ក្នុងឆ្នាំនេះធ្វើឲ្យជនរងគ្រោះនៅក្នុងមន្ទីរពេទ្យ"

សារព័ត៌មាន ឌឹ ញូវ យ៉ក ថាមស៍ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០១ "ការសងសឹកបានបំផ្លាញមុខមាត់ និងព្រលឹងនៅកម្ពុជា"

សារព័ត៌មាន តៃវ៉ាន់ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ២០១០ អាចអានបាន ៖ http://www.taipeitimes.com/News/world/archives/2010/11/18/2003488824/1

វិទ្យុសំឡេងសហរដ្ឋអាមេរិក ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១០ "តុលាការកំពូលតម្កល់សាលក្រមក្នុងករណីអំពើហិង្សាដោយអាស៊ីដ" អាចអានបាន ៖ http://www.voanews.com/khmer-english/news/Supreme-Court-Upholds-Acid-Attack-Verdict-104427959.html (ចូលអានលើកចុងក្រោយ ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២) ។